

# សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

## ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល៖

## ព្រះរាជដំណើរជីវិតពោរពេញទៅដោយព្រឹត្តិការណ៍




# សម្ដេចព្រះមហាក្សត្រ នរោត្ដម មុនិនាថ សីហនុ

## ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គលះ

## ព្រះរាជដំណើរជីវិតពោរពេញទៅដោយព្រឹត្តិការណ៍

# ក្រុមបណ្ណាធិការ

ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

បណ្ឌិតឯកអគ្គរាជទូត ហ្វលីយ៉ូ អេ. ដែលជ្រើស
(© អត្ថបទ និង រូបថត លើកលែងទំព័រកន្លែងណាដែលមានការបញ្ជាក់ផ្សេងពីនេះ)

ក្រុមបោះពុម្ពផ្សាយភាសាអង់គ្លេស និងបកប្រែជាភាសាខ្មែរ
ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា
ហង្ស សុភ័ក្រ្ត ពិធីការ បកប្រែ និងស្រាវជ្រាវ
ម៉ម សុផាត រូបថត និងព័ត៌មានវិទ្យា
អៃឡែន ម៉ាកគីណុន ត្រួតពិនិត្យអត្ថបទ
អ៊ីវេន វ៉ុង របនារូបភាព
សាំង ចិន្ដា បកប្រែ និងស្រាវជ្រាវ
ដារ៉ារដ្ឋ មេត្តា ត្រួតពិនិត្យអត្ថបទជាភាសាខ្មែរ

សេចក្តីថ្លែងអំណរគុណចំពោះ
សម្តេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
ព្រះអង្គម្ចាស់ នរោត្តម រ៉ាវុធ
លោកជំទាវ ខែក ស៊ីសូដា ទីប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ និងជាឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម កែ គឹមសៃ ទីប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ និងជានាយកលេខាធិការដ្ឋានរបស់សម្តេចព្រះមហាក្សត្រី សម្តេចព្រះវររាជមាតាជាតិខ្មែរ
លោកជំទាវ តាំង ម៉េងហ្វួយ កែ គឹមសៃ ទីប្រឹក្សាផ្ទាល់របស់សម្តេចព្រះមហាក្សត្រី សម្តេចព្រះវររាជមាតាជាតិខ្មែរ
លោកជំទាវ ប៉ុក ម៉ារីណា
លោកជំទាវ គ្រិស្ទីន ប៉ែន អ៊ុំ
លោកស្រី ហ្កាយេ រ៉ូហ្កាស្យុង សាលាលីសេអន្តរជាតិ ដេកាត
បណ្ណាសារដ្ឋានជាតិកម្ពុជា
សមុច្ច័យបណ្ណសារសិក្សាស្រាវជ្រាវអំពីអាស៊ី នៃបណ្ណាល័យសាកលវិទ្យាល័យ ម៉ូណាស្ទ

# មាតិកា


៥ បុព្វកថា

៦ ព្រះរាជដំណើរជីវិត៨០ឆ្នាំពោរពេញទៅដោយព្រឹត្តិការណ៍ ដោយព្រះករុណាព្រះបាទ
សម្តេចព្រះបរមនាថ នរោត្តម សីហមុនី

១៧ កំណត់ត្រាដ៏អស្ចារ្យមួយស្តីពីភក្តីភាព ការបរិច្ចាគ ការប្តេជ្ញាហឫទ័យរបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ

៣១ ស្នេហាមួយ ដែលមិនមែនជារឿងព្រេងនិទាន

៤១ ជីវិតនិរទេសក្នុងរយៈពេលដ៏យូរអង្វែង

៥៦ ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា

៧៧ ពង្សាវតាររបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ

៧៩ អវសានកថា



# បុព្វកថា

សៀវភៅនេះ គឺមិនមែនជាការរៀបរាប់ព្រះជីវប្រវត្តិរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ។ ផ្ទុយទៅវិញ សៀវភៅនេះ គឺជាការពណ៌នារំលេចឡើងនូវព្រះហឫទ័យភក្ដី និងបេ្ដជ្ញាចំពោះព្រះរាជកាតព្វកិច្ចរបស់ព្រះអង្គ ដែលជាស្ត្រីដ៏ឆ្នើមមួយរូប នៅក្នុងឱកាសព្រះរាជពិធីចម្រើនព្រះជន្មរបស់សម្ដេចព្រះវររាជមាតាជាតិខ្មែរគម្រប់ជន្មាយុ៨០ ព្រះវស្សា។

សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គមានព្រះជន្មាយុច្រើនក៏ពិតមែន ប៉ុន្ដែព្រះជន្មាយុពុំបានធ្វើឱ្យសភាពក្លៀវក្លាស្រស់ស្រាយរបស់ព្រះអង្គចុះស្រអាប់ ហើយក៏មិនអាចលុបបំបាត់ព្រះរាជសមិទ្ធផលគួរឱ្យកត់សម្គាល់របស់ព្រះអង្គបានដែរ។ ក្នុងព្រះរាជដំណើរជីវិតរបស់ព្រះអង្គ សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គបានឆ្លងកាត់សង្គ្រាម និងភាពវឹកវរក្នុងសង្គម ហើយមិនត្រឹមតែប៉ុណ្ណោះសោត ព្រះអង្គរក្សាបានយ៉ាងខ្ជាប់ខ្ជួននូវព្រះហឫទ័យភក្ដី បរិច្ចាគ និងបេ្ដជ្ញា ចំពោះព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ក៏ដូចជាចំពោះប្រជាជាតិ និងប្រជាជនកម្ពុជាទាំងមូល។

ក្នុងមួយជីវិតរបស់សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គគឺជានិមិត្តរូបនៃមហាកិត្តិយសខ្ពង់ខ្ពស់បំផុត អមដោយព្រះកាយវិការទន់ភ្លន់ជាទីស្រឡាញ់ចំពោះមហាជនទូទៅ។ ព្រះកាយវិការនេះបានធ្វើឱ្យសម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ តែងតែទទួលបាននូវការចាប់អារម្មណ៍ទូទាំងប្រទេស មិនថាក្នុងឱកាសមានទុក្ខព្រួយ ឬក្នុងឱកាសសប្បាយរីករាយ។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅតែបន្ដប្រឈមមុខជាមួយកេរដំណែលមានវិបត្តិបន្សល់ទុកពីប្រវត្តិសាស្ត្រអតីតកាល នៅពេលដែលប្រទេសនេះខិតខំប្រឹងប្រែងប្រកួតប្រជែងនៅក្នុងយុគសម័យមួយដែលពោរពេញទៅដោយភាពប្រញាប់ប្រញាល់ ភាពតានតឹង និងភាពលោភលន់។ ស្ថិតក្នុងកាលៈទេសៈបែបនេះ ភាពកក់ក្ដៅហាក់ដូចជាមានឡើងវិញក្នុងការនឹកមមៃ អំពីសម្ដេច ព្រះមហាក្សត្រី សម្ដេចម៉ែ ដែលជាប្រភព ភាពជឿជាក់រួសរាយ ដែលកម្ពុជាធ្លាប់ទទួលបានពីអតីតកាលកន្លងទៅ។ ព្រះកាយវិការដ៏ទន់ភ្លន់ និងថ្លៃថ្នូររបស់ព្រះអង្គ តែងផ្ដល់ជាឧទាហរណ៍នៃសម្រស់សមសួន និងស្រស់សោភា ក្នុងសម្លៀកបំពាក់ប្រពៃណីជាតិខ្មែរ។

នៅពេលដែលព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ ព្រះអង្គសោយព្រះទិវង្គត នៅក្នុងខែតុលា ឆ្នាំ២០១២ សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គបានយាងទទួលស្វាគមន៍ប្រជាជនកម្ពុជានៅខាងក្រៅរបងព្រះបរមរាជវាំង ក្នុងព្រះភ័ក្ត្រស្រងូតស្រងាត់ ដើម្បីតំណាងជាការកាន់ទុក្ខថ្វាយដល់សម្ដេចព្រះមហាក្សត្រ សម្ដេចឪ នៅទូទាំងប្រទេស។ នៅពេលដែលសម្ដេចម៉ែយកព្រះហស្ដជូតព្រះអស្សុរបស់ព្រះអង្គ ព្រះវត្តមានរបស់ព្រះអង្គ អមដោយព្រះកាយវិការនេះ បានញ៉ាំងឱ្យមានបរិយាកាសពោរពេញទៅដោយភាពសោកសង្រេងយ៉ាងជ្រាលជ្រៅសម្រាប់មនុស្សគ្រប់រូប។

# ដំណើរជីវិត៨០ឆ្នាំ

## ពោរពេញទៅដោយព្រឹត្តិការណ៍

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គមានព្រះជន្មាយុគម្រប់៨០ព្រះវស្សា ហើយទិវាប្រារព្ធពិធីចម្រើនព្រះជន្មរបស់ព្រះអង្គយ៉ាងអធិកអធមនេះក៏ជាខួបលើកទី៦៤ ដែលព្រះអង្គគឺជាសមាជិកព្រះរាជវង្សានុវង្សមួយអង្គ ក្នុងព្រះរាជវង្សត្រកូល ព្រះនរោត្តម នៃព្រះរាជវង្សានុវង្ស ព្រះរាជាណាចក្រកម្ពុជា។

មួយជីវិតរបស់សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ គឺពោរពេញទៅដោយព្រឹត្តិការណ៍ធំៗ រួមមាន ពេលដែលព្រះអង្គត្រូវបង្ខំព្រះហឫទ័យរស់នៅយ៉ាងលំបាក និងអស់រយៈពេលយ៉ាងយូរឆ្ងាយពីមាតុភូមិរបស់ព្រះអង្គ។

ក្នុងនាមជាព្រះមហេសីរបស់ព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងជាទីគួរឱ្យសោកស្ដាយរបស់យើងទាំងអស់គ្នា សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះវររាជមាតាជាតិខ្មែរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គតែងតែខិតខំបំពេញព្រះរាជកាតព្វកិច្ចគ្រប់បែបយ៉ាង ដើម្បីបម្រើដល់កូនចៅដ៏កំសត់របស់ព្រះអង្គ ដែលជាព្រះកាយវិការគំរូសម្រាប់ស្ត្រីខ្មែរ និងតំណាងឱ្យសេចក្ដីថ្លៃថ្នូររបស់ប្រទេសកម្ពុជា។ សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គមានព្រះរាជគុណូបការៈដ៏ធំធេងឧទ្ទិសជីវិតរបស់ព្រះអង្គចំពោះបុព្វហេតុជាតិ។

ក្នុងវ័យកុមារភាព យើងនៅចាំបានថា សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពស្រឡាញ់ គឺជាព្រះប្រជានកាកបាទក្រហមកម្ពុជា ហើយដែលព្រះអង្គបានយកព្រះហឫទ័យទុកដាក់ចំពោះជនរួមជាតិក្នុងគ្រាលំបាក។ សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គតែងតែនៅជិតជាមួយប្រជាជនកម្ពុជា តាមរយៈការបង្ហាញព្រះហឫទ័យខ្វល់ខ្វាយ ការដាក់ព្រះកាយ និងភាពស្រស់ស្រាយមិនចេះរីងស្ងួតរបស់ព្រះអង្គ។

នៅពេលណាដែលយើងមកទស្សនាប្រទេសកម្ពុជា ក្នុងអំឡុងពេលវិស្សមកាលពីការសិក្សា នៅសាលាទីក្រុងប្រាក អតីតប្រទេសឆេកូស្លាវ៉ាគី យើងអមដំណើរសម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជទស្សនកិច្ចទៅកាន់ទីរួមខេត្ត និងស្រុក -ភូមិនានា ព្រះអង្គសព្វព្រះហឫទ័យយាងចែកព្រះរាជអំណោយដល់ជនរងគ្រោះ ដោយសារគ្រោះធម្មជាតិ ការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក ឬ វៀតណាមខាងត្បូង និងសកម្មភាពវិទ្ធង្សនារបស់វៀតកុង។ សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គតែងតែមានព្រះបន្ទូលពាក្យពេចន៍អាណិតអាសូរធ្វើឱ្យជនរងគ្រោះបានធូរស្បើយក្នុងចិត្ត។

នាពេលនោះ យើងទើបតែនឹងបានទៅជួបព្រះមាតា ព្រះបិតារបស់យើងនៅក្នុងទីក្រុងមូស្គូ ហើយនៅ

ក្នុងពេលដែលយើងកំពុងធ្វើដំណើរត្រឡប់ទៅសាលារៀននៅទីក្រុងប្រាកវិញ យើងទទួលបានព័ត៌មានថា ព្រះបិតាជាទីស្រឡាញ់របស់យើងទទួលរងគ្រោះពីរដ្ឋប្រហារ ហើយព្រះមាតាត្រូវបានកាត់ទោសប្រហារជីវិត។ វាគឺជាគ្រាមួយដ៏សែនឈឺចុកចាប់សម្រាប់យើងទាំងអស់គ្នា។

ភ្លាមនោះ ព្រះមាតារបស់យើងព្រះអង្គបានបាត់បែងឱ្យព្រះអង្គម្ចាស់ នរិន្ទ្រពង្ស និងរូបយើងផ្ទាល់ ដើម្បីបន្តការសិក្សារបស់យើងនៅទីក្រុងម៉ូស្គូ និងទីក្រុងប្រាករៀងៗខ្លួន ហើយនៅក្នុងពេលនោះព្រះអង្គបានសរសេរព្រះរាជសារលិខិតផ្ទាល់ព្រះអង្គចំនួនពីរច្បាប់ផ្ញើជូន លោកប្រធានាធិបតីសហភាពសូវៀត និងលោកប្រធានាធិបតីសាធារណរដ្ឋឆែក។ ប្រធានាធិបតីប្រទេសទាំងពីរ ក៏បានឆ្លើយតបតាមព្រះរាជសំណើរបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ដើម្បីផ្តល់អាហារូបករណ៍ដល់រូបយើងទាំងពីរព្រះអង្គ។ នៅពេលនោះ យើងបានស្នាក់នៅក្នុងស្ថានទូតកម្ពុជាប្រចាំទីក្រុងប្រាក។ បន្ទាប់ពីរដ្ឋប្រហារ មន្ត្រីស្ថានទូតខ្មែរទាំងអស់បានប្រកាសភក្តីភាពចំពោះលោកឧត្តមសេនីយ៍ លន់ នល់ ហើយអាជ្ញាធរឆែកបានជួយជ្រោមជ្រែងឱ្យយើងចាកចេញពីស្ថានទូតខ្មែរប្រចាំសាធារណរដ្ឋឆែកទៅស្នាក់នៅក្នុងផ្ទះជាមួយគ្រូម្នាក់មកពីសាលាតូរ្យតន្ត្រីប្រាក។

គ្រានេះគឺជាចំណុចចាប់ផ្តើមនៃទសវត្សរ៍ដ៏សែនលំបាកបំផុតក្នុងជីវិតរបស់ព្រះមាតា ព្រះបិតាជាទីស្រឡាញ់របស់យើង។ ប្រទេសចិន ដែលជាម្ចាស់ផ្ទះ ជាពិសេស លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ បានខិតខំយកអស់លទ្ធភាពធ្វើយ៉ាងណាឱ្យព្រះមាតា ព្រះបិតារបស់យើង មានអារម្មណ៍ស្វាគមន៍ និងផាសុកភាពក្នុងការស្នាក់នៅក្នុងទីក្រុងប៉េកាំង និងបានរៀបចំព្រះរាជដំណើរទស្សនកិច្ចរបស់ព្រះមាតា ព្រះបិតា ទៅកាន់បណ្តាខេត្តនៅប្រទេសចិន ដែលផ្តល់ឱកាសដល់ព្រះអង្គបានស្គាល់កោតសរសើរចំពោះបេតិកភណ្ឌ ក៏ដូចជាការអភិវឌ្ឍរបស់ប្រទេសចិន។

នៅក្នុងទីក្រុងប៉េកាំង សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមិនគ្រាន់តែជាអ្នកផ្តល់ការគាំទ្រផ្នែកស្មារតី និងផ្លូវចិត្តដល់ព្រះបិតាជាទីស្រឡាញ់របស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គតែងតែខិតខំធ្វើយ៉ាងណាឱ្យព្រះបិតាទទួលបានជំនួយចាំបាច់គ្រប់បែបយ៉ាងដែលព្រះអង្គត្រូវការ សម្រាប់បំពេញព្រះរាជកាតព្វកិច្ចសំខាន់ៗរបស់ព្រះអង្គ គឺការទូត និងនយោបាយដើម្បីប្រទេសកម្ពុជា។

ក្រោយខែមេសា ឆ្នាំ១៩៧៥ ព្រះមាតាជាទីស្រឡាញ់របស់យើង ព្រះអង្គបានបំពេញព្រះរាជតួនាទី ជាអ្នកថែទាំ និងជាគ្រូពេទ្យ ក្នុងអំឡុងពេលយើងទាំងអស់គ្នាបានជាប់ឃុំឃាំងក្នុងព្រះបរមរាជវាំង។ ប្រសិនបើមាននរណាម្នាក់ក្នុងចំណោមយើងធ្លាក់ព្រះកាយប្រឈួន សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបំពេញព្រះរាជតួនាទីជាអ្នកព្យាបាលដោយប្រើកញ្ចប់សម្ភារថ្នាំពេទ្យ ដែលព្រះអង្គបានយកតាមព្រះកាយមកពីប្រទេសចិន។ ព្រះមាតា ព្រះអង្គមើលថែទាំយើងទាំងអ



សម្តេចព្រះមហាក្សត្រី សម្តេចម៉ែនាដើមឆ្នាំ១៩៧០។







(រូបខាងលើ រាប់ពីឆ្វេងទៅស្តាំ) ព្រះអង្គម្ចាស់ នរោត្តម ដួងចក្រ; សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និង ព្រះអនុជរបស់ព្រះអង្គ ព្រះនាម ស៊ីសុវត្ថិ អាន-ម៉ារី (ណាណេត) ហ្រ្គាស នៅខែកុម្ភៈ ឆ្នាំ១៩៧០; សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ (លេខ១៤) និងក្រុមបាល់បោះសាលាលីសេអន្តរជាតិ ដេកាត នៅទសវត្សរ៍ឆ្នាំ១៩៥០។ (រូបថតឯកសាររបស់លោកស្រី ហ្កាឡេ រ៉ូហ្គាស្ស៊ុង នៃសាលាលីសេអន្តរជាតិ ដេកាត)





(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ជាមួយ
ព្រះរាជបុត្រាទាំងពីរព្រះអង្គ គឺ ព្រះករុណាព្រះបាទ
សម្តេចព្រះបរមនាថនរោត្តម សីហមុនី (ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា) និងព្រះអង្គម្ចាស់ (សម្តេច) នរោត្តម
នរិន្ទ្រពង្ស (១៩៥៤-២០០៣)។

(រូបខាងក្រោម) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ
ជាមួយព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម
សីហមុនី ព្រះមហាក្សត្រ និងព្រះករុណាព្រះបាទ សម្តេចព្រះ
នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ
បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ។

សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គយាងទស្សនា
ប្រាសាទអង្គរវត្ត នៅខែមីនា ឆ្នាំ១៩៧៣។













(រូបខាងលើ រាប់ពីឆ្វេងទៅស្តាំ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គអមដំណើរដោយភរិយាមេដឹកនាំចិន រួមមាន ជំទាវ ហ្សាង គាំង (ភរិយារបស់លោក ចិន យី), ជំទាវ វ៉ាង គួងម៉ី (ភរិយារបស់លោក លីយូ សាវគី) និងជំទាវ គេង យីងតាវ (ភរិយារបស់លោក ជូ អេនឡាយ); នៅទសវត្សរ៍ឆ្នាំ៦០: សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមានព្រះរាជវត្តមាននៅក្នុងដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីបារាំង ហ្សាល ឌឺហ្គោល មកកាន់ប្រទេសកម្ពុជានៅឆ្នាំ១៩៦៦។ (រូបកណ្តាល រាប់ពីឆ្វេងទៅស្តាំ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និងសម្តេចព្រះមហាក្សត្រ សម្តេចឪ ព្រះអង្គនៅទីក្រុងប៊ែលក្រាដ ក្នុងសន្និសីទកំពូលរបស់ចលនាមិនចូលបក្សសម្ព័ន្ធ។ នៅឆ្នាំ១៩៦៥: សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គប្រគេនចង្ហាន់ដល់សម្តេចសង្ឃរាជ ជួន ណាត។ (រូបខាងក្រោម រាប់ពីឆ្វេង) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបំពេញព្រះរាជតួនាទីជាព្រះប្រធានកាកបាទក្រហមកម្ពុជា ក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ព្រះអង្គយាងចុះសួរសុខទុក្ខ និងចែកព្រះរាជអំណោយជូនដល់អ្នកជំងឺទាំងឡាយណាសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ និង សម្រាកព្យាបាលជំងឺ។

ស់គ្នាយ៉ាងជិតដល់គួរឱ្យស្ញប់ស្ញែងយ៉ាងក្រៃលែង។

អស់រយៈពេល៦០ឆ្នាំ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គមិនគ្រាន់តែបានបំពេញព្រះរាជតួនាទីជាព្រះមហេសី និងជាដៃគូជីវិតពោរពេញទៅដោយភក្ដីភាពរបស់សម្តេចព្រះមហាក្សត្រ សម្តេចឳ ជាទីស្រឡាញ់ នាពេលព្រះអង្គគង់នៅជានាយករដ្ឋមន្ត្រី ជាព្រះប្រមុខរដ្ឋ ជាមេដឹកនាំចលនាប្រឆាំង និងជាព្រះមហាក្សត្រ តែប៉ុណ្ណោះទេ ប៉ុន្តែសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គតំណាងឱ្យ "ព្រះវីរភាពនៃភាពរឹងមាំ" របស់ព្រះរាជវង្សានុវង្ស ផ្តល់ការគាំទ្រស្មារតីដល់សម្តេចព្រះមហាក្សត្រ សម្តេចឳ ដែលព្រះអង្គត្រូវការចាំបាច់បំផុតក្នុងដំណាក់កាលមួយដ៏សែនលំបាក ដើម្បីឱ្យព្រះអង្គអាចបំពេញព្រះរាជតួនាទីនយោបាយ និងការទូត ជាប្រយោជន៍ដល់ប្រជាជនកម្ពុជា។

បន្ថែមលើនេះ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គក៏បានបំពេញព្រះរាជតួនាទីជាព្រះមាតាដល់ព្រះអនុជព្រះរៀមរបស់យើង ដែលជាបុត្រាបុត្រីរបស់សម្តេចព្រះមហាក្សត្រ សម្តេចឳនៃយើង បន្ទាប់ពីព្រះមាតារបស់ព្រះអនុជព្រះរៀមទាំងនោះផ្ទាល់ បានសោយទិវង្គត ដោយសារព្រះរោគាពាធ ឬការកាប់សម្លាប់រង្គាលដោយខ្មែរក្រហម។

សម្រាប់ប្រជាជាតិ និងព្រះរាជវង្សានុវង្សនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជពិធីចម្រើនព្រះជន្មរបស់សម្តេចព្រះវររាជមាតាជាតិខ្មែរគម្រប់ជន្មាយុ៨០ព្រះវស្សានាពេលនេះ គឺជាឱកាសដ៏វិសេសវិសាលសម្រាប់យើងក្នុងការថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅបំផុតថ្វាយ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ព្រះមាតាជាទីស្រឡាញ់ ដែលព្រះអង្គតែងតែបូជាព្រះកាយក្នុងការបំពេញព្រះរាជកាតព្វកិច្ចបម្រើ និងផ្តល់ក្តីសង្ឃឹមដល់យើង ធ្វើឱ្យយើងទាំងអស់គ្នាមានមោទកភាពណាស់ដែលបានកើតជាប្រជាជនកម្ពុជា។ យើងប្រាកដក្នុងចិត្តណាស់ថា ប្រជាជនកម្ពុជាទាំងអស់ នឹងចូលរួមជាមួយយើង ក្នុងការប្រារព្ធព្រះរាជពិធីអបអរសាទរបំពោះទិវាដ៏អធិកអធមនេះ ដោយក្តីសោមនស្សរីករាយ និងជាទីមោទន។

ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា



*សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និងសម្តេចព្រះមហាក្សត្រ សម្តេចឪ ជាមួយបុត្រាទាំងពីរព្រះអង្គ និងព្រះអង្គម្ចាស់ក្សត្រិយ៍ (សម្តេច) នរោត្តម សុរិយា រង្សី។*





*(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ជាមួយសម្តេចរាជបុត្រីព្រះរៀម បុប្ផា ទេវី ក្នុងកិច្ចសន្ទនាជាមួយ អតីតស្ត្រីទី១អាមេរិក ជំទាវ ហ្សាក់គ្លីន ខែនណឺឌី នៅឆ្នាំ១៩៦៧។ (រូបខាងក្រោម) សម្តេចព្រះមហាក្សត្រ សម្តេចឪ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និង សម្តេច សឺន សាន នាយករដ្ឋមន្ត្រី លើកកែវស្រាអបអរសាទរវត្តមានរបស់ អតីតស្ត្រីទីមួយអាមេរិក ជំទាវ ហ្សាក់គ្លីន ខែនណឺឌី ក្នុងព្រះរាជពិធីសោយភោជនាហារផ្លូវការដើម្បីស្វាគមន៍ដំណើរ ទស្សនកិច្ចរបស់ជំទាវមកកាន់ប្រទេសកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ១៩៦៧។*

# សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ

## កំណាត់ត្រាដ៏អស្ចារ្យមួយស្តីពីភក្តីភាព

## ការបរិច្ចាគ និងការប្តេជ្ញាហាបុន័យ



សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្នុងទសវត្សរ៍ឆ្នាំ១៩៦០។

សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានប្រសូតនៅទីក្រុងសៃហ្គន ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៣៦ និងទទួលបានព្រះនាមដើម ប៉ូល-ម៉ូនិក អ៊ីហ្ស៊ី (Paule-Monique Izzi) ដែលជាចំណាងអាពាហ៍ពិពាហ៍រវាងអ្នកស្រី ប៉ុម ពាង និងលោក ហ្សង់-ហ្វ្រង់ស្វ័រ អ៊ីហ្ស៊ី (Jean-Francois Izzi) ជនជាតិបារាំងមានដើមកំណើតអ៊ីតាលី ដែលជានាយកគ្រប់គ្រងរបស់ធនាគារក្រេឌីតហ្វុងស៊័រ ប្រចាំទីក្រុងភ្នំពេញ និងទីក្រុងសៃហ្គន។ ធនាគារក្រេឌីតហ្វុងស៊័រ គឺជាធនាគារតម្កល់វត្ថុបញ្ចាំរបស់ប្រទេសបារាំង ដែលបានបើកសាខាប្រតិបត្តិការនៅឥណ្ឌូចិន។

លោក ហ្សង់-ហ្វ្រង់ស្វ័រ អ៊ីហ្ស៊ី ធ្លាប់ជាមិត្តជិតស្និទ្ធមួយរូបរបស់ព្រះករុណាព្រះបាទ ព្រះនរោត្តម សុរាម្រិត ព្រះបិតារបស់ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ។ អ្នកស្រី ប៉ុម ពាង គឺជាកូនស្រីរបស់អ្នកស្រី អ៊ុក ដែលបានរៀបអាពាហ៍ពិពាហ៍ ជាមួយព្រះអង្គម្ចាស់ នរោត្តម ដួងចក្រ ដែលត្រូវជាបុត្រាច្បងរបស់ព្រះកុណាព្រះបាទ នរោត្តម អតីតព្រះមហាក្សត្រ។

ម៉ូនិក អ៊ីហ្ស៊ី បានបញ្ចប់ការសិក្សាកម្រិតបឋមភូមិនៅវិទ្យាល័យព្រះនរោត្តម ហើយបន្ទាប់មកបានបន្តការសិក្សារហូតដល់បញ្ចប់កម្រិតសិក្សាបំណេះទូទៅនៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងក្រោយមកទៀត នៅសាលាលីសេអន្តរជាតិ ដេកាត ក្នុងរាជធានីភ្នំពេញ។

សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពកីឡានៅសាលាលីសេអន្តរជាតិ ដេកាត តាមរយៈសមាជិកភាពរបស់ព្រះអង្គនៅក្នុងក្រុមបាល់ទះ និងបាល់បោះប្រចាំសាលា។

ក្នុងខែមេសា ឆ្នាំ១៩៥២ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ និងបន្ទាប់មកទៀតទទួលបានព្រះគោរមងារជាព្រះមហាក្សត្រី។ សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមានបុត្រាពីរព្រះអង្គ គឺព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ប្រសូតនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៣ និងឡើងសោយរាជ្យជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤ និងសម្តេច នរោត្តម នរិន្ទ្រពង្ស ប្រសូតនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៥៤ ប៉ុន្តែគួរឱ្យសោកស្តាយព្រះអង្គបានសោយទិវង្គត នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៣។

ក្នុងចុងទសវត្សរ៍ឆ្នាំ១៩៥០ និងទសវត្សរ៍ឆ្នាំ១៩៦០ សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គគឺជាបាហុនិកាដ៏រូសរាយ និងមានសម្រស់ស្រស់ស្អាត នៅក្នុងការធ្វើបដិសណ្ឋារកិច្ចទទួលស្វាគមន៍ប្រមុខរដ្ឋជាច្រើន ដែលបានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា និងក្នុងការហែព្រះរាជដំណើរព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ នៅក្នុងពេលព្រះអង្គយាងបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋទៅកាន់ប្រទេសបារាំង អង្គការសហប្រជាជាតិ ប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ី។

ព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ ព្រះអង្គតែងតែចាត់ទុកថា ការធ្វើបដិសណ្ឋារកិច្ចទទួលស្វាគមន៍កក់ក្ដៅបំផុត ដល់ភ្ញៀវបរទេសដែលមកធ្វើទស្សនកិច្ចជាផ្លូវការ គឺមានសារសំខាន់ណាស់ ហើយសម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ជានិច្ចជាកាល ព្រះអង្គតែងតែយាងហែព្រះរាជដំណើររបស់ព្រះមហាក្សត្រទៅកាន់បណ្ដាខេត្តនានា ដើម្បីជានាឱ្យមានការរៀបចំចាត់ចែងឱ្យហើយត្រឹមត្រូវស្រេចបាច់ មុនពេលមកដល់នៃដំណើរទស្សនកិច្ចផ្លូវការរបស់ប្រមុខរដ្ឋ ឬតំណាងរដ្ឋាភិបាលបរទេស។

ក្នុងប្រទេស សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គបានបំពេញព្រះរាជតួនាទីជាព្រះប្រធានកាកបាទក្រហមកម្ពុជា ចាប់តាំងពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៧០ នៅពេលដែលរដ្ឋប្រហាររបស់លោកឧត្តមសេនីយ៍ លន់ នល់ បានរុញច្រានប្រទេសកម្ពុជាឱ្យធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាម ឆេះរាលដាលមកពីប្រទេសវៀតណាម។

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ កាកបាទក្រហមកម្ពុជា បានដើរតួនាទីសំខាន់មួយក្នុងការផ្ដល់ជំនួយឧបត្ថម្ភគាំទ្រដល់ប្រជាជនកម្ពុជា ដែលទទួលរងការលំបាកពីការលុកលុយទន្ទ្រានរបស់កងទ័ពវៀតកុង សហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង ចូលក្នុងទឹកដីរបស់ប្រទេសកម្ពុជា។ កាកបាទក្រហមកម្ពុជាបានបំពេញបេសកកម្មមនុស្សធម៌បន្ថែមទៀត ដោយបានដើរតួជាអន្តរការីរវាងគ្រួសាររបស់ទាហានឈ្លើយសឹកអាមេរិក និងអាជ្ញាធរវៀតកុង រហូតដល់ការជួយសម្របសម្រួលឱ្យមានការដោះលែងឈ្លើយសឹកទាំងនោះបានជាច្រើននាក់ទៀតផង។

បន្ទាប់ពីលោកឧត្តមសេនីយ៍ លន់ នល់ ធ្វើរដ្ឋប្រហារ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្ដេចព្រះមហាក្សត្រ សម្ដេចព្រះមហាក្សត្រី សមាជិករាជរដ្ឋាភិបាល និងព្រះរាជវង្សានុវង្ស ទទួលបានសិទ្ធិជ្រកកោនក្នុងទឹកដីនៃសាធារណរដ្ឋប្រជាមានិតចិន។ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៥ សម្ដេចព្រះមហាក្សត្រ សម្ដេចព្រះមហាក្សត្រី សមាជិករាជរដ្ឋាភិបាល និងព្រះរាជវង្សានុវង្ស ដែលទទួលបានសិទ្ធិជ្រកកោនក្នុងប្រទេសចិន បានវិលត្រឡប់មកនៅកម្ពុជាវិញ។ ចាប់ពីខែធ្នូ ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ សម្ដេចព្រះមហាក្សត្រ សម្ដេចព្រះមហាក្សត្រី និងបុត្រាទាំងពីរព្រះអង្គ គឺព្រះអង្គម្ចាស់ព្រះបាទ នរោត្តម សីហមុនី និងព្រះអង្គម្ចាស់ ព្រះបាទ នរោត្តម នរិន្ទ្រពង្ស រស់នៅក្រោមការឃុំឃាំងនៅក្នុង



(រូបថត) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងចូលរួម
ក្នុងព្រះរាជពិធីទិវាដាំកូនឈើជាតិ នៅឆ្នាំ១៩៩៦។

ព្រះបរមរាជវាំង ទីក្រុងភ្នំពេញ។

ទោះបីជាស្ថិតក្នុងស្ថានភាពលំបាកបែបនេះក្តី សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គជានិច្ចជាកាល សម្តែងនូវព្រះកាយវិការមេត្តាស្រឡាញ់ និងអាណិតអាសូរបំពោះអ្នកដទៃទៀតជុំវិញព្រះអង្គ ដែលជួបការខ្វះខាត ឬឈឺថ្កាត់ជាដើម។

ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គបានរំឭកថា នៅក្នុងអំឡុងពេលជាច្រើនឆ្នាំ ដែលសមាជិកព្រះរាជវង្សានុវង្សទាំងអស់ ត្រូវស្ថិតក្រោមការឃុំឃាំងនៅក្នុងព្រះរាជដំណាក់ខេមរិន្ទ ក្នុងទីក្រុងភ្នំពេញ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គនៅតែផ្តល់ការថែទាំដោយផ្ទាល់ជូនព្រះរាជវង្សានុវង្សគ្រប់រូបនៅក្នុងព្រះរាជដំណាក់។

ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គមានព្រះបន្ទូលរំឭកដូច្នេះថា៖

*"យើងនៅចាំបានថា មានថ្ងៃមួយនោះ មានស្ត្រីម្នាក់ដែលកំពុងស្នាក់នៅជាមួយយើង បានដួលបែកក្បាល។ ពេលនោះ ព្រះមាតារបស់យើងបានរត់ទៅយកកញ្ចប់សម្ភារពេទ្យរបស់ព្រះអង្គ ទាញឧបករណ៍ចេញមកធ្វើការផ្គូតសម្អាតមុខរបួសជ្រៅនេះ មុននឹងដេរភ្ជិតមុខរបួសទៅវិញ។"*

បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅខែតុលា ឆ្នាំ១៩៩១ ដែលបញ្ចប់ការនិរទេសព្រះកាយជាលើកទីពីររបស់ព្រះរាជវង្សានុវង្ស សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ បានយាងធ្វើមាតុភូមិនិវត្តន៍វិញនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ គឺនៅពេលនោះហើយដែលសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គក៏បានយាងចូលប្រឡូកនៅក្នុងព្រះរាជកិច្ចសកម្មភាពរបស់កាកបាទក្រហមកម្ពុជាសាជាថ្មីឡើងវិញ។

នៅឆ្នាំ១៩៩២ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គទទួលបានការដំឡើងព្រះបរមងារជា "សម្តេចព្រះជាយា" ហើយបន្ទាប់ពីការប្រកាសជាផ្លូវការ រដ្ឋធម្មនុញ្ញថ្មី នៅខែកញ្ញា ឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានផ្លាស់ប្តូរទៅជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញជាថ្មីម្តងទៀត។ ព្រះរាជបល្ល័ង្កត្រូវបានថ្វាយព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ដែលព្រះអង្គបានទទួលការអភិសេកជា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានទទួលព្រះរាជឋានៈជា "សម្តេចព្រះអគ្គមហេសី" ដែលគឺជា "ព្រះមហាក្សត្រីនៃព្រះរាជាណាចក្រកម្ពុជា" ជាមួយនឹងព្រះនាម នរោត្តម មុនិនាថ សីហនុ។

ក្រោយមកទៀត សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានទទួលព្រះរាជទានព្រះបរមងារជា












(រូបខាងលើ រាប់ពីឆ្វេងទៅស្តាំ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ជាមួយសិក្ខាកាមវគ្គបណ្តុះបណ្តាល កាកបាទក្រហមកម្ពុជា ក្នុងទសវត្សរ៍ឆ្នាំ១៩៦០; ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះវររាជបិតាជាតិ ព្រះបរមរតនកោដ្ឋ, ព្រះអង្គម្ចាស់ នរោត្តម ខេមានុរក្ស និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ (ព្រះអង្គម្ចាស់ ខេមានុរក្ស បានបាត់ព្រះកាយរហូត ចាប់តាំងពីឆ្នាំ១៩៧៦); ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះវររាជបិតាជាតិ ព្រះបរមរតនកោដ្ឋ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះវររាជមាតាជាតិ ជាមួយសម្តេចរាជបុត្រីព្រះរៀម បុប្ផា ទេវី នៅឆ្នាំ១៩៩៧។



សម្តេចព្រះមហាក្សត្រី
សម្តេចម៉ែ ទ្រង់គង់ប្រថាប់
នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ
នៃព្រះបរមរាជវាំង
ក្នុងទសវត្សរ៍ឆ្នាំ១៩៩០។



KRET

NOUS
NORODOM SIHANOUK
Roi du Cambodge

Accordons
à notre Epouse
le titre
de

Sa Majesté Preah Reach Akka-Mohesey
NORODOM MONINEATH SIHANOUK
du Cambodge

Nsihanouk

Fait en notre Palais Royal, à Phnom Penh
le 2 janvier 1996





(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងសួរសុខទុក្ខប្រជាជន នៅជំរំជនភៀសខ្លួនខៅអុីដាង នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៨២។ រូបខាងក្រោម៖ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ ព្រះអង្គយាងសួរសុខទុក្ខជនភៀសខ្លួនកម្ពុជានៅជំរំសាយប៊ី តាមព្រំដែនកម្ពុជា-ថៃ ក្នុងខែកក្កដា ឆ្នាំ១៩៨៧។



សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងសួរសុខទុក្ខជនភៀសខ្លួនកម្ពុជានៅជំរំភ្នំម៉ាឡៃ
នៅតាមព្រំដែនកម្ពុជា-ថៃ ក្នុងឆ្នាំ១៩៨៣។





(រូបខាងលើ) បន្ទាប់ពីព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ សោយព្រះទិវង្គត នៅខែតុលា ឆ្នាំ២០១២ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានទទួលនូវការអាណិតស្រឡាញ់កាន់តែខ្លាំងឡើងពីសំណាក់ប្រជាជនកម្ពុជា ដែលបានមកប្រមូលផ្តុំគ្នារាប់ពាន់នាក់រៀងរាល់ថ្ងៃនៅមុខព្រះបរមរាជវាំង ដើម្បីចូលរួមចែករំលែកទុក្ខសោកជាមួយ “សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ”។ រូបខាងក្រោម៖ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ យាងទទួលស្វាគមន៍ប្រជាជនកម្ពុជានៅខាងក្រៅរបងព្រះបរមរាជវាំង នៅខែតុលា ឆ្នាំ២០១២។



ព្រះរាជពិធីសម្ពោធមជ្ឈមណ្ឌលថែទាំមនុស្សចាស់ព្រះសីហនុរាជ្យ នៅខែសីហា ឆ្នាំ២០១៥។

"សម្តេចព្រះរាជអគ្គមហេសី" ក្នុងព្រះរាជក្រឹត្យប្រកាសនៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៩៦។

បន្ទាប់ពីព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គបានដាក់រាជ្យលែងគង់នៅជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាតទៅទៀត រដ្ឋសភាជាតិ ជាឯកច្ឆន្ទ បានថ្វាយព្រះគោរមងារដល់ព្រះមហាក្សត្រី សម្តេចម៉ែ ជាសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា ឬ ព្រះមហាក្សត្រី សម្តេចម៉ែ នៃព្រះរាជាណាចក្រកម្ពុជា។

នៅពេលណាដែលព្រះអង្គគង់ផុតពីក្រសែភ្នែកមហាជន សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គតែងតែមានព្រះកាយវិការដូចប្រជាជនសាមញ្ញយ៉ាងសុទ្ធសាធ ពោរពេញទៅដោយព្រះរាជតម្រិះខ្វល់ខ្វាយចំពោះអ្នកដទៃ ដែលជាលក្ខណៈសម្បត្តិគួរឱ្យស្ញប់ស្ញែងមួយក្នុងនាមជា ព្រះមហាក្សត្រី។ លើសពីនេះទៅទៀត បើទោះបីជាព្រះអង្គយាងទៅណាមកណាក្នុងនាមជាឥស្សរជនសាធារណៈយ៉ាងណាក៏ដោយ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គនៅតែរក្សាបានព្រះកាយវិការប្រៀបបានជាបុគ្គលសាមញ្ញមួយរូប ដែលជាចំណុចធ្វើឱ្យប្រជាជនកម្ពុជាដឹងគុណ និងគោរពស្រឡាញ់ចំពោះព្រះអង្គយ៉ាងខ្លាំង។

យ៉ាងណាមិញ នៅពីក្រោយព្រះកាយវិការសាមញ្ញ និងសុភាពរាបសាររបស់ព្រះអង្គ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមានព្រះរាជតម្រិះចំណេះដឹងជ្រៅជ្រះអំពីរាល់ព្រឹត្តិការណ៍កើតឡើងបច្ចុប្បន្ននៅប្រទេសកម្ពុជា។ ព្រះមហាក្សត្រី ឈួរ នៃព្រះរាជាណាចក្រហូឡង់ជានី បានជួបធ្វើសវនាការជាមួយសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៅក្នុងអំឡុងពេលធ្វើទស្សនកិច្ចផ្លូវការមកកាន់ប្រទេសកម្ពុជា នាខែតុលា ឆ្នាំ១៩៩២ ហើយក្រោយមកព្រះមហាក្សត្រីបានសព្វព្រះរាជហឫទ័យសរសេរព្រះរាជសារលិខិតថា ព្រះអង្គមានព្រះហឫទ័យចាប់អារម្មណ៍យ៉ាងខ្លាំងនៅពេលដែលបានស្គាល់អំពីភាពរួសរាយ និងចំណេះដឹងជ្រៅជ្រះរបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ជុំវិញរឿងសោកនាដកម្មដោយសារបញ្ហាគ្រាប់មីននៅកម្ពុជា។

ក្នុងពេលថ្មីៗកន្លងទៅនេះ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានអំពាវនាវឱ្យមានការបញ្ចប់ការជួញដូរ និងអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី។ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមានព្រះរាជបន្ទូលថា *"ទង្វើរំលោភបំពានលើរាងកាយ និងការជួញដូរ បានបណ្តាលឱ្យមានការបាត់បង់សេចក្តីថ្លៃថ្នូររបស់ស្ត្រី និងក្មេងស្រី និងនាំទៅរកការបាក់បែកតម្លៃគ្រួសារទៀតផង។"*៣

នៅពេលណាដែលព្រះអង្គទទួលបានការហែហមដោយប្រជាជនសាមញ្ញ ព្រះកាយវិការបន្ទាបព្រះកាយរបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ កម្រនឹងមិនបានទទួលនូវការកត់សម្គាល់ណាស់ មិនត្រឹមតែប៉ុណ្ណោះសោតព្រះកាយ

វិការនេះរំលេចឱ្យឃើញនូវព្រះមហាក្សត្រីលាក់ព្រះកាយមួយអង្គ។ រាល់ទង្វើរបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ បញ្ជាក់ឱ្យឃើញថា ព្រះអង្គចាត់ទុកប្រជាជនជុំវិញព្រះអង្គថាជាមនុស្សស្មើភាពគ្នាដូចព្រះអង្គដែរ ដែលជាទិដ្ឋភាពមួយគួរឱ្យរំភើបចិត្ត គ្រប់ពេលព្រះអង្គស្ថិតនៅជាមួយប្រជាជនកម្ពុជារបស់ព្រះអង្គ។

សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមានប្រជាប្រិយភាពយ៉ាងខ្លាំងក្នុងប្រទេសកម្ពុជា ជាពិសេសនៅតាមតំបន់ជនបទ ដែលមានប្រជាជនកម្ពុជាជាច្រើននៅតែចាត់ទុក រាជានិយម ប្រៀបបានទៅនឹងទេវរូបដ៏រុងរឿងត្រចះត្រចង់។ ការប្តេជ្ញាហឫទ័យរបស់ព្រះអង្គក្នុងនាមជាអ្នកបម្រើមនុស្សធម៌មិនចេះនឿយហត់បានធ្វើឱ្យសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ កាន់តែទទួលបានប្រជាប្រិយភាពខ្លាំងឡើងៗនៅតាមបណ្តាសហគមន៍។

ជារៀងរាល់ថ្ងៃទី១៨ ខែមិថុនា ប្រជាជនកម្ពុជានាំគ្នាប្រារព្ធព្រះរាជពិធីចម្រើនព្រះជន្មាយុរបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ដោយហៅថ្ងៃនេះថា *«ទិវាសម្តេចម៉ែ»*។ នៅតាមទីក្រុងតូចធំ មានការតុបតែងលម្អ ជាមួយព្រះឆាយាល័ក្ខណ៍របស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និងទង់ជាតិកម្ពុជា ដែលបញ្ជាក់ឱ្យឃើញនូវភក្តីភាព និងការគោរពដ៏ឧត្តុង្គឧត្តមចំពោះសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៃកម្ពុជា។

ចាប់តាំងពី ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ សោយព្រះទិវង្គតនាខែតុលា ឆ្នាំ២០១២ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គនៅតែបន្តធ្វើព្រះរាជសកម្មភាពមនុស្សធម៌ ដែលបានផ្តួចផ្តើមដោយសម្តេចព្រះមហាក្សត្រ សម្តេចឪ ជាប្រយោជន៍ដល់ជនរួមជាតិកម្ពុជាដ៏កំសត់របស់ព្រះអង្គ រួមមានការសាងសង់សាលារៀន ការបង្កើតមជ្ឈមណ្ឌលសម្រាកព្យាបាល ការជីកស្រះត្រី និងការផ្តល់ជំនួយឧបត្ថម្ភដល់ជនពិការ និងអ្នកជំងឺជាដើម។

ទន្ទឹមគ្នានេះដែរ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គក៏សព្វព្រះរាជហឫទ័យប្រោសព្រះរាជឧបត្ថម្ភព្រះរាជទ្រព្យដល់ការសាងសង់មជ្ឈមណ្ឌលថែទាំមនុស្សចាស់ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្នុងរាជធានីភ្នំពេញ។ មជ្ឈមណ្ឌលនេះត្រូវបានសាងសង់ឡើងដោយការចំណាយថវិកាអស់ចំនួន២,៩លានដុល្លារអាមេរិក ដែលជាព្រះរាជអំណោយរបស់ព្រះអង្គ និងការបរិច្ចាគរបស់ព្រះរាជវង្សានុវង្ស និងម្ចាស់ជំនួយដទៃទៀត។

# ស្នេហាមួយដែលមិនមែនជារឿងព្រេងនិទាន



ព្រះមហាក្សត្រ និងព្រះមហាក្សត្រី ទាំងពីរព្រះអង្គ នៅប្រទេសបារាំង នាដើមទសវត្សរ៍ឆ្នាំ១៩៧០។

នៅថ្ងៃច័ន្ទ ទី៣០ ខែមករា ឆ្នាំ១៩៥៦ ទស្សនាវដ្តីថាម៍ របស់សហរដ្ឋអាមេរិក បានចុះផ្សាយអំពីអត្ថបទព័ត៌មានមួយក្រោមចំណងជើងថា *“ម៉ូនិក ជួបជាមួយព្រះមហាក្សត្រ”* ដោយសរសេរទាំងខុសឆ្គងថា នារីឈ្មោះ ប៉ូល-ម៉ូនិក អ៊ីហ្ស៊ី ដែលជាសិស្សមានរាងស្តើង តូចច្រឡឹង សក់ពណ៌ទង់ដែង រៀននៅសាលាលីសេអន្តរជាតិ ដេកាត មិនចង់រៀបការជាមួយជនជាតិអឺរ៉ុបទេ ប៉ុន្តែមានគំនិតចង់រៀបការជាមួយព្រះអង្គម្ចាស់កម្ពុជាមួយអង្គវិញ។

យោងតាមអត្ថបទក្នុងទស្សនាវដ្តីនេះ ម៉ូនិក ដែលជាកូនស្រីមានម្តាយខ្មែរ និងឪពុកជាជនជាតិបារាំងកាត់អ៊ីតាលី ធ្វើការនៅធនាគារក្រេឌីតហ្វុងស័រ ប្រចាំនៅឥណ្ឌូចិន បានឃើញព្រះភក្ត្រព្រះមហាក្សត្រវ័យក្មេងមួយព្រះអង្គរបស់ប្រទេសកម្ពុជា ជាលើកដំបូង នៅក្នុងកម្មវិធីប្រកួតបវរកញ្ញា ដែលរៀបចំឡើងដោយអង្គការយូណេស្កូ នៅក្នុងរាជធានីនៃប្រទេសកម្ពុជា។៤




Pour
celle que j'aime et admire le plus
au monde, après mon auguste
Maman, pour celle qui a tant
fait pour moi : mon épouse,
S.A.R. la Princesse Norodom
Monique, avec ma plus profonde
affection et mon immense
reconnaissance.

Le 6 Juillet 1984





សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គសព្វព្រះរាជហឫទ័យតន្ត្រីដូចព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ដែលទាំងពីរព្រះអង្គ ជារឿយៗតែងច្រៀងលេងកំសាន្តជាមួយគ្នា។






តាមការពិត អនាគតព្រះមហាក្សត្រីមួយអង្គនេះធ្លាប់បានស្គាល់ព្រះមហាក្សត្រ តាំងពីព្រះអង្គមានព្រះជន្មាយុវ័យក្មេងម្ល៉េះ ពីព្រោះឪពុករបស់ព្រះនាង លោកហ្សង់-ហ្វ្រង់ស្វ័រ អ៊ីហ្ស៊ី ធ្លាប់ជាមិត្តជិតស្និទ្ធម្នាក់របស់ព្រះករុណាព្រះបាទ ព្រះសុរាម្រិត ហើយម្តាយរបស់ព្រះនាង គឺអ្នកស្រី ប៉ុម ពាង ក៏ធ្លាប់ជាមិត្តជិតស្និទ្ធរបស់ព្រះអយ្យិកា និងព្រះអយ្យកោរបស់ព្រះមហាក្សត្រ គឺព្រះអង្គម្ចាស់ និងព្រះនាង នរោត្តម សុត្ថារ័ត្ន។[៥]

លោក អ៊ីហ្ស៊ី ដែលចូលចិត្តស្រឡាញ់ព្រះរាជវង្សត្រកូលព្រះសុរាម្រិតខ្លាំង តែងតែទៅលេងព្រះរាជដំណាក់របស់ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សុរាម្រិត  ស្ថិតនៅមហាវិថីឡេងស៊ីសុវត្ថិ (នៅជិតវិមានឯករាជ្យ)។ ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សុរាម្រិត មិនដែលរង្កៀសព្រះហឫទ័យដោយសារវត្តមានរបស់លោកអ៊ីហ្ស៊ីនោះទេ។ ស្របពេលគ្នានោះដែរ លោក អ៊ីហ្ស៊ី ជារឿយៗនាំមកថ្វាយព្រះមហាក្សត្រវ័យក្មេង ព្រះករុណាព្រះបាទ ព្រះនរោត្តម សីហនុ សៀវភៅរូបភាពជាច្រើនមកពីប្រទេសបារាំង រួមមានដូចជាសៀវភៅរឿង “អាលីបាបា” “រាប់ពាន់រាត្រី និងមួយរាត្រី” និង “ប៊ីកូដ ប៊ីកូទីន” ជាដើម។

នៅពេលដែលយុវនារី ម៉ូនិក មានវ័យ១២ឆ្នាំ នាងបានអមដំណើរម្តាយរបស់នាងទៅលេងព្រះរាជដំណាក់របស់ព្រះអង្គម្ចាស់ និងអ្នកម្នាង សុរាម្រិត ដែលនៅទីនោះហើយនាងបានជួបព្រះអង្គម្ចាស់វ័យក្មេង នរោត្តម សីហនុ ហើយព្រះអង្គម្ចាស់វ័យក្មេងមួយព្រះអង្គនេះមានព្រះបន្ទូលទៅកាន់អ្នកស្រី ប៉ុម ពាង ថា នៅប៉ុន្មានឆ្នាំខាងមុខ ព្រះអង្គនឹងសុំចូលដណ្តឹងនាងម៉ូនិក យកធ្វើជាព្រះមហេសី ដាក់ជាមិនខាន។ ប៉ុន្តែពេលនោះ អ្នកស្រី ប៉ុម ពាង បានឆ្លើយតបវិញថា៖

*“ព្រះអង្គម្ចាស់ ព្រះអង្គគឺជាព្រានពនារីដ៏ល្បីល្បាញមួយអង្គ។ រៀងរាល់៦ខែ ព្រះអង្គម្ចាស់ដូរស្រីស្នេហ៍ម្តង។ ដូច្នេះ ពេលណាដែលនាងត្រូវមានប្តី សូមទុកឱ្យកូនស្រីរបស់ទូលព្រះបង្គំស្វែងរកប្តីល្អ និងមានភក្តីភាពម្នាក់បានហើយ។ ប្តីមួយប្រពន្ធមួយ មិនមែនប្តីមួយស្រីច្រើនដូចព្រះអង្គម្ចាស់ទេ។”*[៦]

ប៉ុន្មានឆ្នាំក្រោយមកទៀត នៅក្នុងកម្មវិធីប្រកួតបវរកញ្ញាមួយដែលរៀបចំឡើងដោយអង្គការយូណេស្កូ ព្រះមហាក្សត្រវ័យក្មេងមួយអង្គនេះ ព្រះអង្គមានព្រះវត្តមាននៅក្នុងកម្មវិធីនេះដែរ និងបានជំរុញលើកទឹកចិត្តឱ្យនាង ម៉ូនិក ចូលរួមប្រកួតប្រជែង ប៉ុន្តែនាងមិនបានត្រៀមខ្លួនទេ ហើយបានសួរទៅកាន់ព្រះអង្គវិញទាំងភាពអឹមអៀនថា៖ *«ព្រះអង្គបើសិនជាខ្ញុំមិនឈ្នះ ខ្ញុំពិតជាយំហើយ ដូច្នេះតើព្រះអង្គនឹងធ្វើអ្វីទៅដើម្បីលួងខ្ញុំឱ្យបាត់យំ?»*[៧]

ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គមានព្រះបន្ទូលតបទៅវិញថា ប្រសិនបើនាងមិនមានសំណាងក្នុងការដណ្តើមជ័យជម្នះបានទេនោះ ព្រះអង្គនឹងប្រទានពានប្រាក់ដែលមានក្បាច់ឆ្លាក់ដ៏ល្អបំផុតមួយ ហើយពេលនោះអ្នកចូលរួមក្នុងកម្មវិធីនោះនឹងនាំគ្នាទះដៃអបអរសាទរដល់នាង ម៉ូនិក យ៉ាងអធិកអធម។[៨]

នៅក្នុងព្រឹត្តិការណ៍នោះ អនាគតព្រះមហាក្សត្រខ្មែរបានទទួលជ័យលាភីជាបរិវកញ្ញា ហើយមិនយូរប៉ុន្មានក្រោយមកទៀតព្រះមហាក្សត្រវ័យក្មេង ព្រះករុណាព្រះបាទ ព្រះនរោត្តម សីហនុ ព្រះអង្គបានស្នើសុំការអនុញ្ញាតពីអ្នកស្រី ប៉ុម ពាង ចូលស្តីដណ្តឹងនាង ម៉ូនិក ធ្វើជាព្រះមហេសី ដោយពេលនោះជាអកុសល លោក អ៊ីហ្ស៊ី បានស្លាប់បាត់បង់ជីវិតបាត់ទៅហើយនៅក្នុងសង្គ្រាមលោកលើកទីពីរ។

អ្នកស្រី ប៉ុម ពាង យល់ព្រមព្រះរាជសំណើឱ្យកូនស្រីរៀបអាពាហ៍ពិពាហ៍ជាមួយព្រះករុណាព្រះបាទ ព្រះនរោត្តម សីហនុ បន្ទាប់ពីទទួលបានការផ្តល់ប្រឹក្សាយោបល់បញ្ចុះបញ្ចូលពីសំណាក់ឃុនព្រះម្នាង ប៉ុប្ផា នរល័ក្ខ មាឃ ដែលជាស្ត្រីចាស់ទុំ ក្នុងចំណោមព្រះមេហសីមេម៉ាយរបស់អតីតព្រះមហាក្សត្រ ស៊ីសុវត្ថិ មុនីវង្ស និងដែលជាព្រះមាតារបស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ គុស្សរៈ ហើយនិងដែលជាជីដូនមួយ និងជាដៃគូរ៉ៃបាល់តេន្នីសរបស់ព្រះមហាក្សត្រ ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ។

នៅក្នុងឆ្នាំ១៩៥២ ក្នុងព្រះរាជពិធីអបអរអាពាហ៍ពិពាហ៍ដែលនឹងមកដល់ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គបានព្រះនិពន្ធចម្រៀងមួយបទ ក្នុងចំណោមបទចម្រៀងដែលនិយមចូលចិត្តជាច្រើនរបស់ព្រះអង្គ មានចំណងជើងថា «រាត្រីដែលបានជួបភក្ត្រ» ជាចង្វាក់ ឆា ឆា ឆា ដែលមានទំនុកច្រៀងថាៈ

*"មុនដួចនារី រសាត់តាមរាតាបក់នាំទៅឆ្ងាយ ... ត្បែរបអូនសោភា មានលក្ខណ៍សែនឆើតឆាយ ... អូន*

*អើយបងសប្បាយ ព្រោះបងបាន កែវពន្លកដួចបំណង មកធ្វើជាគូគ្រង លុះគ្រាអវសាន។"៩*

នៅឆ្នាំ១៩៥៣ ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គបានព្រះនិពន្ធចម្រៀងមួយបទទៀត ជាចង្វាក់បូឡេរ៉ូ មានចំណងជើងថា ម៉ូនិកា (ម៉ូនិកា គឺជាពាក្យ "ម៉ូនិក" បកប្រែទៅជាភាសាអ៊ីតាលី និងអេស្ប៉ាញ) ដែលតាមរយៈនោះ ព្រះអង្គជាថ្មីម្តងទៀតបានសម្តែងព្រះហឫទ័យស្នេហារបស់ព្រះអង្គចំពោះសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ដែលមានទំនុកច្រៀងដូចខាងក្រោមៈ

*"ម៉ូនិកា អូនស្អាតណាស់ ប្រៀបបាននឹងតារាមានពន្លឺដ៏ស្រទន់នាពេលរាត្រី ... ម៉ូនិកា ស្នេហាដ៏ផ្អែមល្ហែមរបស់បងអើយ។ ស្នេហា សំណើច និងសម្រស់រូបកាយរបស់អូនបានធ្វើឱ្យរង្វង់ដៃទទេររបស់បងពេញទៅដោយសេចក្តីសុខសុភមង្គល។ ម៉ូនិកា អូនជាពិភពលោកសម្រាប់បង អូនស្ថិតក្នុងអារម្មណ៍របស់បងជានិច្ច អូនជាស្នេហ៍ពិតរបស់បងតែមួយគត់។"១០*

បន្ទាប់ពីបទចម្រៀង ម៉ូនិកា នៅឆ្នាំ១៩៥៤ ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ






*(រាប់ពីឆ្វេងទៅស្តាំ) ព្រះរាជពិធីចម្រើនព្រះជន្មាយុ៥០ព្រះវស្សារបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៅទីក្រុងព្យុងយ៉ាង នៅខែមិថុនា ឆ្នាំ១៩៨៦; សម្តេចព្រះមហាក្សត្រ សម្តេចឪ និងព្រះមហាក្សត្រី សម្តេចម៉ែ ក្នុងខ្សែភាពយន្ត មានចំណងជើងថា “ពេលព្រះអាទិត្យអស្តង្គត”; សម្តេចព្រះមហាក្សត្រ សម្តេចឪ និងព្រះមហាក្សត្រី សម្តេចម៉ែ ជាភ្ញៀវកិត្តិយសរបស់រដ្ឋាភិបាល ចិន ក្នុងពិធីរំឭកខួបអនុស្សាវរីយ៍នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន នៅទីធ្លាធៀនអានមិន នៅទីក្រុងប៉េកាំង នៅខែតុលា ឆ្នាំ២០១១; ទីក្រុងព្យុងយ៉ាង នៅឆ្នាំ១៩៨២។*



*សម្តេចព្រះមហាក្សត្រ សម្តេចឪ និងព្រះមហាក្សត្រី សម្តេចម៉ែ ក្នុងខ្សែភាពយន្ត មានចំណងជើងថា “ពេលព្រះអាទិត្យអស្តង្គត” នៅឆ្នាំ១៩៦៩។*

ព្រះអង្គបានព្រះនិពន្ធបម្រៀងមួយបទទៀត ជាចង្វាក់ រុមបា ក្រោមចំណងជើងថា កុលាបភ្នំពេញដែលនៅក្នុងបទចម្រៀងនោះ ព្រះអង្គបានបញ្ជាក់ឡើងវិញសាជាថ្មីអំពីព្រះហឫទ័យប្រតិព័ទ្ធរបស់ព្រះអង្គចំពោះសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺចាប់តាំងពីពេលនោះមក ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានផ្លាស់ប្តូរព្រះកាយធ្វើជាព្រះស្វាមីឯកពន្ធ ដោយព្រះអង្គបានបោះបង់បោលនូវប្រពៃណីព្រះមហាក្សត្រខ្មែរមានព្រះជាយាច្រើន ដែលធ្លាប់មានពីមុនអស់ជាច្រើនសតវត្សរ៍មកហើយ។

រឿងស្នេហារបស់សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ មានអាយុកាល៦០ឆ្នាំរហូតដល់ខែតុលា ឆ្នាំ២០១២ នៅពេលដែលព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គសោយព្រះទិវង្គត។

# ជីវិតនិរទេសដ៏យូរអង្វែង

នៅពេលព្រះអង្គមានព្រះជន្មាយុ៣៤ព្រះវស្សា ជីវិតរបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ទទួលរងការប្រែប្រួលយ៉ាងគំហុក និងទាំងស្រុង ដោយព្រះអង្គ និងសម្តេចព្រះមហាក្សត្រ សម្តេចឪ ត្រូវរស់នៅនិរទេសក្នុងប្រទេសចិន។ នៅខែកក្កដា ឆ្នាំ១៩៧២ ក្នុងបទសម្ភាសន៍លើកដំបូងរបស់ព្រះអង្គ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមានព្រះរាជបន្ទូលសារភាពថា ព្រះអង្គមានការប្រែប្រួលខុសពីមុន។១១

*"កាលពីមុន យើងមិនដែលស្គាល់ជីវិតនយោបាយទេ។ យើងមិនដែលចូលប្រឡូកក្នុងនយោបាយទេ។ ព្រះហឫទ័យខ្វល់ខ្វាយរបស់យើងតែមួយគត់ គឺបេសកកម្មរបស់កាកបាទក្រហម និងភារកិច្ចផ្លូវការរបស់យើងក្នុងនាមជាព្រះមហេសីរបស់ព្រះប្រមុខរដ្ឋ។១២"*

ព្រះអង្គមានព្រះរាជបន្ទូលថែមទៀតថា ចាប់តាំងពីមានរដ្ឋប្រហារមក ព្រះអង្គត្រូវបង្ខំព្រះហឫទ័យចូលប្រឡូកសកម្មនៅក្នុងជីវិតនយោបាយ ដោយត្រូវខិតខំស្វែងយល់អំពីកិច្ចការអន្តរជាតិ និង ជាពិសេស កាលៈទេសៈនានាជុំវិញសភាពការណ៍ក្នុងប្រទេសកម្ពុជា។

*"កាលពីមុន ជីវិតរស់នៅរបស់យើងមានភាពសាមញ្ញបំផុត ... ប៉ុន្តែពេលនេះមានសភាពស្មុគស្មាញបន្តិច។ បន្ទាប់ពីថ្ងៃរំដោះ (ប្រទេសកម្ពុជា) យើងមានព្រះតំរិះថាជីវិតនយោបាយរបស់យើង នឹងនៅតែបន្តបែបនេះទៀតមើលទៅ។១៣*

កិច្ចសម្ភាសន៍នោះបានធ្វើឡើងនៅក្នុងទីក្រុងស្ទិនយ៉ាង នាភាគឦសាននៃប្រទេសចិន ក្នុងខែកក្កដា ឆ្នាំ១៩៧២ ជាពេលមួយដែលគ្មាននរណានឹកស្មានបានថា ប្រទេសកម្ពុជានឹងត្រូវបានរំដោះផុតចេញពីរបប លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ប៉ុន្តែបែរជាត្រូវរងគ្រោះដោយសារអំពើតាមទំនើងចិត្តរបស់ ប៉ុល ពត និងបក្សពួកខ្មែរក្រហម ដែលបានឃុំឃាំងសម្តេចព្រះមហាក្សត្រ សម្តេចឪ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និងគ្រួសាររបស់ព្រះអង្គផ្ទាល់ឱ្យស្ថិតនៅក្នុងព្រះបរមរាជវាំង។

នៅទីក្រុងប៉េកាំង សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបំពេញព្រះរាជតួនាទីជាព្រះរាជលេខារបស់សម្តេចព្រះមហាក្សត្រ សម្តេចឪ ក្នុងនោះមានការរៀបចំលិខិតឯកសារ ការស្រង់ព័ត៌មាន និងការកត់ទុកនូវព័ត៌មានលើទំព័រកាសែតដែលទាក់ទងទៅនឹងសភាពការណ៍នៅក្នុងប្រទេសកម្ពុជា។

នៅក្នុងកិច្ចសម្ភាសន៍ដដែលនោះ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ បានសារភាពថា ទោះបីជាព្រះរាជកាតព្វកិច្ចនេះថ្មីសម្រាប់ព្រះអង្គក្តី ប៉ុន្តែព្រះអង្គនៅតែយល់ថា នេះជាផ្នែកមួយដ៏សំខាន់នៃការឧទ្ទិសកម្លាំងកាយចិត្តរបស់ព្រះអង្គចំពោះការរំដោះប្រទេសកម្ពុជា។ ទន្ទឹមគ្នានោះ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គនៅតែបន្តព្រះរាជសកម្មភាពរបស់ព្រះអង្គ



សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងបំពេញព្រះរាជទស្សនកិច្ចទៅកាន់វាំងចាស់
នៅក្រៅទីក្រុងប៉េកាំង ក្នុងទសវត្សរ៍ឆ្នាំ១៩៧០។


尊敬的诺罗敦·西哈努克亲王阁下：

顷收到你亲手做的三种名贵的菜，特向你表示衷心地感谢！你亲手做的菜，看起来很美好，吃起来一定更美味。你对我们的那亲密和珍贵的友谊，使我们非常感动！现由谨表，专诚致谢。请你接受我们最诚挚的敬意和良好的友谊和问候。同样向你的夫人致意！

邓颖超 周恩来
一九七二年二月七日

*សារលិខិតសរសេរដោយដៃរបស់ជំទាវ តេង យិងចាវ និងលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ នៅឆ្នាំ១៩៧០។*

សេចក្តីប្រែសម្រួល ក្នុងសារលិខិតរបស់លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ថ្វាយព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ
ចុះនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧២។

សម្តេចព្រះ នរោត្តម សីហនុ ជាទីគោរព!

យើងបានទទួលរួចហើយនូវអាហារចំនួនបីចានដែលព្រះអង្គបានរៀបចំចម្អិនដោយផ្ទាល់ព្រះហស្ត។ អាហារទាំងនេះពិតជាមានសម្រស់ប្រពៃ និងឱជារសខ្លាំងណាស់។ យើងមានសេចក្តីរំភើបក្នុងចិត្តក្រៃលែង ដោយសារព្រះរាជកាយវិការដ៏ថ្លៃថ្លា និងព្រះហឫទ័យមិត្តភាពមិនអាចកាត់ថ្លៃបាន ដែលព្រះអង្គបានព្រះប្រទានចំពោះយើង។ តាមរយៈនេះ យើងគ្មានភាពអល់អែកទេក្នុងការផ្ញើជូនព្រះអង្គនូវសេចក្តីថ្លែងអំណរគុណជាថ្មីម្តងទៀត។

សូមព្រះអង្គព្រះមេត្តាទទួលយកនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ព្រមទាំងមិត្តភាព និងសេចក្តីរាប់អានអំពីយើង និងសូមផ្ញើជូនសេចក្តីនឹករឭកចំពោះព្រះមហាក្សត្រី ម៉ូនិក។

តេង យិងឆាវ
ជូ អេនឡាយ

ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧២

ជាព្រះប្រធានកាកបាទក្រហមកម្ពុជាដដែល ក្រោមក្របខណ្ឌនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។

មិនយូរប៉ុន្មានបន្ទាប់ពីមានរដ្ឋប្រហារ នៅខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គស្រងាកព្រះហឫទ័យ និងមានអារម្មណ៍ថាទទួលរងសេចក្តីក្បត់ព្រះហឫទ័យ ដោយសារទង្វើរបស់បុគ្គលមួយចំនួននៅភ្នំពេញ ដែលព្រះអង្គតែងតែចាត់ទុកថាជាមិត្តល្អរបស់ព្រះអង្គ។ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមានព្រះបន្ទូលថា៖

*"គឺមនុស្សទាំងនេះឯង យើងធ្លាប់ចាត់ទុកថាជាមិត្តល្អ ដែលជាអ្នកក្បត់យើងមុនគេ។"*[១៤]

បន្ទាប់ពីមានរដ្ឋប្រហារ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ យុទ្ធនាការត្រៀមរៀបចំទុកជាមុន បានចាប់ផ្តើមចេញសកម្មភាពប្រឆាំងទៅនឹងសម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រមទាំងគ្រួសារព្រះរាជវង្សានុវង្សផ្ទាល់របស់ព្រះអង្គ ដែលត្រូវបានចោទប្រកាន់ថា បានបើកផ្លូវឱ្យបរទេសយកទឹកដីកម្ពុជាប្រើប្រាស់សម្រាប់ដឹកជញ្ជូនសព្វាវុធទៅឱ្យកងទ័ពវៀតកុង។[១៥] មិនមានភ័ស្តុតាងអ្វីទាល់តែសោះនៅពីក្រោយការចោទប្រកាន់នេះ ប៉ុន្តែផ្ទុយទៅវិញ តាមពិតក្រោយមកទៀត នៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០ មានរបាយការណ៍ជាច្រើនដែលអាជ្ញាធរសហរដ្ឋអាមេរិក និងអូស្ត្រាលីបានបញ្ចេញឱ្យដឹងថា សព្វាវុធទាំងនោះត្រូវបានរត់ពន្ធឆ្លងកាត់ប្រទេសកម្ពុជាដោយពាណិជ្ជករលាក់លៀមមួយរូប ដែលមានសញ្ជាតិចិន-ខ្មែរ និងមានឈ្មោះថា គុជ អាន ដោយជននេះបានធ្វើប្រតិបត្តិការរត់ពន្ធសព្វាវុធនេះចេញពីទឹកដីហុងកុង ដែលខ្លួនកំពុងរស់នៅក្នុងនិរទេស នាពេលនោះ។[១៦]

បុគ្គល គុជ អាន នេះគឺជាបរិស័ទមួយរូបរបស់លោកឧត្តមសេនីយ៍ លន់ នល់ ហើយត្រូវបាននិរទេសខ្លួនចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ១៩៦៧ បន្ទាប់ពីមានជម្លោះជាមួយមន្ត្រីកម្ពុជាច្រើននាក់ក្នុងរឿងក្តីពីការប៉ុនប៉ងសូកប៉ាន់ក្នុងគោលបំណងឱ្យមន្ត្រីទាំងនោះសហការជាមួយខ្លួនក្នុងសកម្មភាពរត់ពន្ធ។[១៧] បុគ្គល គុជ អាន នេះបានទៅតាំងទីលំនៅក្នុងទីក្រុងហុងកុង និងចូលដៃជាមួយមនុស្សម្នាក់ទៀតក្នុងការបង្កើតក្រុមហ៊ុនដឹកជញ្ជូន ហាក់ លី ក្នុងប្រទេសកម្ពុជា និងក្រុមហ៊ុនដឹកជញ្ជូនតាមនាវាមួយទៀតនៅក្នុងទីក្រុងហុងកុង ដោយប្រើប្រាស់នាវាសម្រាប់ ដឹកជញ្ជូនអាវុធចេញពីទីនោះមកឆ្លងកាត់ប្រទេសកម្ពុជាទៅឱ្យកងទ័ពវៀតកុង។[១៨]

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានធ្វើសន្និសីទសារព័ត៌មានមួយនៅក្នុងទីក្រុងប៉េកាំង ដែលនាពេលនោះព្រះអង្គមានព្រះបន្ទូលថា *"ព្រះអង្គក្តី និងព្រះស្វាមីរបស់ព្រះអង្គក្តី មិនមានទ្រព្យសម្បត្តិមហាសាល ហើយក៏មិនមានគណនីធនាគារនៅចក្រភពអង់គ្លេស ឬនៅប្រទេសស្វ៊ីសនោះទេ។"*[១៩]

សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គមានព្រះបន្ទូលបន្ថែមទៀតថា *"ព្រះនាមរបស់យើងកំពុងត្រូវបាន*

*អ្នកសកាត់កក់ដ៉ៅ។ សត្រូវរបស់យើងកំពុងតែប្រឹងនិយាយពាក្យភូតកុហកអំពីយើងទាំងពីរព្រះអង្គមិនចេះចប់មិនចេះហើយ។*២០

នៅពេលដែលការចោទប្រកាន់ខាងលើត្រូវបានទីភ្នាក់ងារចារកម្មចាត់ទុកថាជា *"ភ័ស្តុតាងផ្អែកលើការយល់ឃើញ"* មិនអាចសម្រេចផលជាវិជ្ជមានបានយុទ្ធនាការនោះក៏បានផ្លាស់ប្តូរយុទ្ធវិធីរបស់ខ្លួនដោយចោទគ្មានភ័ស្តុតាងថា សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ធ្លាប់បានលួចធ្វើដំណើរចេញពីប្រទេសកម្ពុជា នៅក្នុងខែមករា ឆ្នាំ១៩៧០ ដោយនាំយកទៅជាមួយនូវមាសជាច្រើនកេស ដែលក្រោយមកត្រូវបានយកទៅប្រើប្រាស់សម្រាប់ចំណាយលើការសាងសង់ព្រះរាជដំណាក់របស់ព្រះអង្គនៅក្នុងទីក្រុងប៉េកាំង និងទីក្រុងព្យុងយ៉ាង។

ការចោទប្រកាន់នេះគឺខុសទាំងស្រុង។ ព្រះរាជដំណាក់នៅទីក្រុងប៉េកាំង និងទីក្រុងព្យុងយ៉ាង បានសាងសង់ឡើងដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ ថ្វាយសម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ប្រើប្រាស់ស្នាក់នៅក្នុងពេលនិរទេសរបស់ព្រះអង្គទាំងពីរ។

បន្ទាប់ពីខ្មែរក្រហមបានឡើងគ្រប់គ្រងអំណាចនៅប្រទេសកម្ពុជា នៅមានការប៉ុនប៉ងចុងក្រោយមួយទៀតដើម្បីប្រមាថសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ជាមួយការចោទប្រកាន់ថា ព្រះអង្គមានសុទិដ្ឋិនិយមខ្លាំងណាស់អំពីអនាគតរហូតដល់ថ្នាក់ថា នៅខែកញ្ញា ឆ្នាំ១៩៧៥ ព្រះអង្គបានបញ្ជាទិញមកុដមួយសម្រាប់ព្រះអង្គពីក្រុមហ៊ុនលក់គ្រឿងអលង្ការមួយឈ្មោះ "Cartier" នៅទីក្រុងប៉ារីស ដែលជាក្រុមហ៊ុនច្នៃម៉ូតគ្រឿងអលង្ការដ៏ថ្លៃបំផុតក្នុងចំណោមក្រុមហ៊ុនល្បីៗលើពិភពលោក។២១

នៅចំពេលដែលការចោទប្រកាន់នេះបានកើតឡើង មានការចេញផ្សាយដោយទស្សនាវដ្តីល្បីឈ្មោះមួយនៅទីក្រុងហុងកុងថា សម្តេចព្រះមហាក្សត្រ សម្តេចឪ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និងបុត្រាទាំងពីរព្រះអង្គបានក្លាយខ្លួនជាអ្នកទោស ជាប់ឃុំឃាំងរបស់ខ្មែរក្រហមរួចបាត់ទៅហើយ ក្នុងព្រះបរមរាជវាំង ទីក្រុងភ្នំពេញស្របពេលដែលព្រះរាជវង្សានុវង្សផ្ទាល់របស់ព្រះអង្គជាច្រើន ព្រះអង្គទៀតបានបាត់ព្រះកាយលែងរស់រានមានជីវិតតទៅទៀតដោយសារស្នាដៃរបស់ខ្មែរក្រហម។ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គធ្លាប់បានរំឭកឡើងដូច្នេះថា៖

*"មានមនុស្សច្រើននាក់ណាស់ដែលមិនបានដឹងថា យើងបាត់បង់ព្រះរៀមព្រះអនុជទាំងប្រាំព្រះអង្គនៅក្នុងសម័យសង្គ្រាម ព្រមទាំងបុត្រាបុត្រីរបស់ព្រះរៀមព្រះអនុជទាំងអស់គ្នា ដប់មួយព្រះអង្គទៀត។ រីឯយើងទាំងបួនព្រះអង្គត្រូវ*





(រូបខាងលើ) សម្តេចព្រះមហាក្សត្រ សម្តេចឪ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និង សមាជិកព្រះរាជវង្សានុវង្សរបស់ព្រះអង្គ បន្ទាប់ពីទស្សនាការប្រកួតកីឡាវាយសី នៅទីក្រុងប៉េកាំង ក្នុងទសវត្សរ៍ឆ្នាំ១៩៧០។
(រូបខាងឆ្វេង) សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៅក្នុងព្រះរាជដំណើរយាងទស្សនកិច្ចនៅតាម «តំបន់រំដោះក្នុងប្រទេសកម្ពុជា» ដែលបានរៀបចំឡើងដោយថ្នាក់ដឹកនាំខ្មែរក្រហមនៅឆ្នាំ១៩៧៦។



*(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ អមដំណើរដោយជំទាវ គីម អ៊ីលស៊ុង យាងព្រះរាជទស្សនកិច្ច រោងចក្រមួយនៅក្នុងទីក្រុងព្យុងយ៉ាងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០។ (រូបខាងក្រោម) សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ យាងព្រះរាជទស្សនកិច្ចនៅផ្នូរសពលោកប្រធានាធិបតី ចូស៊ិប ប្រ៊ុហ្ស ទីតូ នៃអតីតយូហ្គោស្លាវី ក្នុងទសវត្សរ៍ឆ្នាំ១៩៨០។*





(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និងព្រះរៀមរបស់ព្រះអង្គ គឺព្រះអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ អាន់-ម៉ារី (ណាណែត) យាងថែទាំព្រះមហាក្សត្រិយានី ស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្នសេរីវឌ្ឍនា នៅទីក្រុងប៉េកាំង ឆ្នាំ១៩៧៤។ (រូបខាងក្រោម) ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ សម្តេចព្រះមហាក្សត្រ សម្តេចឪ និងជំទាវ តេង យិងចាវ (ភរិយារបស់លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ) នៅឆ្នាំ១៩៧៩។











*សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៅទីក្រុងប៉ារីស បន្ទាប់ពីរំដោះព្រះកាយរួចផុតពីរបបខ្មែរក្រហម នៅឆ្នាំ១៩៧៩។*

*ជាប់ឃុំឃាំងនៅក្នុងព្រះបរមរាជវាំង ជាមួយស្រ្តីបីនាក់ទៀត ដែលជាមិត្តជិតស្និទ្ធរបស់ព្រះមាតាយើង។*២២

ពេលរស់នៅក្នុងជីវិតនិរទេស នាទីក្រុងប៉េកាំង សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានបំពេញព្រះរាជតួនាទីជាលេខាធិការរបស់សម្តេចព្រះមហាក្សត្រ សម្តេចឪ ដោយព្រះអង្គជួយរៀបចំលិខិតឆ្លងឆ្លើយ និងបំពេញព្រះរាជតួនាទីជាព្រះប្រធានកាកបាទក្រហមកម្ពុជា នៅក្រោមក្របខណ្ឌនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គផ្អាកព្រះរាជកិច្ចនេះ នៅពេលសោយព្រះក្រយាថ្ងៃត្រង់តែប៉ុណ្ណោះ បន្ទាប់ពីព្រះអង្គសម្រាកសោយព្រះក្រយាថ្ងៃត្រង់រួចបន្តិចមក ព្រះអង្គក៏ចាប់ផ្តើមបន្តព្រះរាជកិច្ចរបស់ព្រះអង្គតទៅទៀត។ នៅពេលល្ងាចសម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ វាយសី ឬក៏ទស្សនាខ្សែភាពយន្តកម្សាន្ត។

លោក ជូ អេនឡាយ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន និងជំទាវ តេង យិងចាវ គឺជាម្ចាស់ផ្ទះយ៉ាងល្អប្រពៃ ហើយលោកទាំងពីរតែងតែអញ្ជើញមកសួរសុខទុក្ខ ឬផ្ញើអាហារចម្អិនថ្មីៗថ្វាយជូនសម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ អមជាមួយពាក្យពេចន៍លើកទឹកចិត្ត និងមិត្តភាពមកជាមួយផង។ ថ្នាក់ដឹកនាំចិន បានរៀបចំឱ្យមាននូវព្រះរាជដំណើរទស្សនកិច្ចរបស់សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ទៅកាន់រមណីយដ្ឋានបុរាណៗ និងការដ្ឋានអភិវឌ្ឍន៍ថ្មីៗនៅជុំវិញប្រទេសចិន។ នៅទីនោះសម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ តែងតែទទួលបាននូវការស្វាគមន៍ជាមួយការគោរពខ្ពង់ខ្ពស់ និងភាពស្និទ្ធស្នាល ជានិច្ចពីសំណាក់ប្រជាជនចិន។

ជាកិច្ចឆ្លើយតបវិញសម្តេចព្រះមហាក្សត្រ សម្តេចឪ បានចម្អិនអាហារខ្មែរ ឬបារាំងផ្ញើជូនលោកនាយករដ្ឋមន្ត្រី និងជំទាវ ដែលតែងតែយកចិត្តទុកដាក់ខ្លាំងក្នុងការថែទាំសុខទុក្ខរបស់ព្រះអង្គ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ។ នៅចន្លោះខែមីនា និងខែមេសា ឆ្នាំ១៩៧៣ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានសម្តែងនូវព្រះវីរភាពក្លាហានដោយព្រះអង្គយាងអមសម្តេចព្រះមហាក្សត្រ សម្តេចឪ នៅក្នុងព្រះរាជដំណើរយ៉ាងវែងឆ្ងាយត្រឡប់ចូលប្រទេសកម្ពុជាវិញតាមគន្លងផ្លូវលំហូជីមិញ ដើម្បីធ្វើទស្សនកិច្ច ដែលមានរយៈពេលជិតមួយខែ។ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គសរសេរកំណត់ត្រាទុកនៅក្នុងព្រះទិនានុលេខន៍កំណត់ហេតុប្រចាំថ្ងៃរបស់ព្រះអង្គថា "នៅក្នុងដំណើរនោះ ព្រះអង្គទាំងពីរអាចជួបគ្រោះថ្នាក់ពីការទម្លាក់គ្រាប់បែករបស់យន្តហោះយោធាអាមេរិក។"

សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានអមដំណើរសម្តេចព្រះមហាក្សត្រ សម្តេចឪ នៅក្នុងព្រះរាជដំណើរទស្សនកិច្ចផ្លូវរដ្ឋទៅកាន់ទីក្រុងអាល់បានី ប្រទេសរ៉ូម៉ានី និងអតីតយូហ្គោស្លាវី ក្នុងខែកក្កដា ឆ្នាំ១៩៧៣ ហើយក្រោយមកទៀត នៅឆ្នាំ១៩៧៤ និង១៩៧៥ ទៅបណ្តាប្រទេសអាហ្វ្រិក ដែលជាប្រទេសគាំទ្រយ៉ាងខ្លាំងក្លាដល់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៣ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្នសេរីវឌ្ឍនា ត្រូវបានរដ្ឋាភិបាលអនុញ្ញាតឱ្យចាកចេញពីប្រទេសកម្ពុជា មកគង់នៅជាមួយសម្ដេចព្រះ នរោត្តម សីហនុ នៅក្នុងប្រទេសចិន។ សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គពិនិត្យលើការចាត់ចែងគ្រប់បែបយ៉ាង តាមតែអាចធ្វើទៅបាន ដើម្បីរៀបចំធ្វើយ៉ាងណាឱ្យការគង់នៅរបស់ព្រះមហាក្សត្រិយានីមានផាសុកភាពជាទីបំផុត។




*ក្នុងព្រះរាជតួនាទីជាព្រះប្រធានកាកបាទក្រហមកម្ពុជា នៅក្នុងក្របខណ្ឌរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គយាងព្រះរាជទស្សនកិច្ចមន្ទីរពេទ្យមួយនៅទីក្រុងហាណូយ បន្ទាប់ពីទទួលរងការទម្លាក់គ្រាប់បែកនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០។*

# ឯកអគ្គរាជទូត

## នៃព្រះរាជាណាចក្រកម្ពុជា

មាត្រា១៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ១៩៩៣ ចែងថា ព្រះមហេសី នៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ។២៣

មាត្រានេះចែងបន្តទៀតថា ព្រះមហេសី នៃព្រះរាជាណាចក្រកម្ពុជា ទុកព្រះរាជកាយពលបំពេញព្រះរាជភារៈ បម្រើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រក្នុងព្រះរាជកាតព្វកិច្ចផ្នែកពិធីការ និងការទូត។

សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គតែងតែគោរពជាប់ជានិច្ចចំពោះរដ្ឋធម្មនុញ្ញ នៅក្នុងរាល់ព្រះរាជកិច្ចសកម្មភាពរបស់ព្រះអង្គ ចាប់តាំងពីឆ្នាំ១៩៩៣ រហូតដល់វេលាដែល ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គបានដាក់រាជ្យនៅឆ្នាំ២០០៤ ហើយដែលនៅពេលនោះ រដ្ឋសភាជាតិកម្ពុជាបានអនុម័តថ្វាយព្រះគោរមងារផ្លូវការដល់ សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ អមដោយព្រះបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិគ្រប់បែប យ៉ាងដូចនឹងព្រះបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ព្រះមហាក្សត្រកំពុងគ្រងរាជសម្បត្តិ។

យ៉ាងណាក៏ដោយ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែបានបំពេញព្រះរាជតួនាទីការទូតសំខាន់មួយនៅក្នុងការស្វែងរកដំណោះស្រាយជម្លោះកម្ពុជា ដែលសកម្មភាព នេះមិនសូវមាននរណាដឹងឮនោះទេ។

រឿងរ៉ាវបានចាប់ផ្តើមឡើងបន្ទាប់ពីមានការវាយប្រហារប្រដាប់អាវុធរបស់កងទ័ពខ្មែរក្រហម ទៅលើកងទ័ពជាតិ សីហនុនិយម នៅដើមខែឧសភា ឆ្នាំ១៩៨៧ ដែលបានធ្វើឱ្យកងទ័ពមួយចំនួនបានស្លាប់បាត់បង់ជីវិត។ ឧបទ្ទវហេតុនេះ ធ្លាប់កើតមានពីមុនៗមកដែរ ប៉ុន្តែដើម្បីរក្សាឱ្យបាននូវឯកភាពក្នុងចំណោមកងកម្លាំងទ័ពឧទ្ទាម ដែលតែងតែមានភាព តានតឹងជាមួយគ្នា (ក្នុងនោះមានកងទ័ពហ្វ៊ុនស៊ិនប៉ិច កងទ័ពរណសិរ្សជាតិរំដោះប្រជាជនកម្ពុជា និងភាគីកម្ពុជា ប្រជាធិបតេយ្យ ខ្មែរក្រហម) សម្តេចព្រះ នរោត្តម សីហនុ មិនបានធ្វើអត្ថាធិប្បាយជាសាធារណៈណាមួយទេ ផ្ទុយទៅ វិញព្រះអង្គបានសរសេរសារលិខិតទៅកាន់ដៃគូក្នុងសម្ព័ន្ធភាពនេះ ដោយទាក់ទាញការចាប់អារម្មណ៍ទៅលើបញ្ហារំលោភ សិទ្ធិមនុស្ស។

បន្ថែមលើនេះ ក្នុងអត្ថាធិប្បាយជាសំណេរផ្ទាល់ព្រះហស្តលើព្រឹត្តបត្រព័ត៌មានប្រចាំខែរបស់ព្រះអង្គសម្តេច ព្រះនរោត្តម សីហនុ បានព្រមានដកព្រះកាយចេញពីរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើ ភាគី កម្ពុជាប្រជាធិបតេយ្យ មិនយល់ព្រមបញ្ឈប់ការរំលោភសិទ្ធិមនុស្ស មិនទៅលើកងទ័ពសីហនុនិយមតែប៉ុណ្ណោះទេ ប៉ុន្តែទៅ



សម្តេចព្រះអគ្គមហេសី សម្តេចម៉ែ ជាមួយលោកជំទាវ ស្ហ៊ីរ៉ាក់ នៅទីក្រុងប៉ារីស នៅឆ្នាំ១៩៩៦។

លើជំរំជនភៀសខ្លួនក្រោមការគ្រប់គ្រងរបស់កងទ័ពខ្មែរក្រហមនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ដូចត្រូវបានលើកឡើងជាច្រើនលើកនៅក្នុងរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ។

ទោះជាយ៉ាងណាក៏ដោយ ស្ថានការណ៍មានការប្រែប្រួល នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៨៧ នៅពេលដែលសម្ដេចព្រះ នរោត្ដម សីហនុ ទទួលបានរបាយការណ៍សម្ងាត់មួយស្ដីពីព្រះអង្គម្ចាស់ នរោត្ដម រណឫទ្ធិ ដោយរាយការណ៍ថ្វាយព្រះអង្គអំពីការវាយប្រហារខាងលើពីសំណាក់កងទ័ពខ្មែរក្រហមទៅលើកងកម្លាំងសីហនុនិយម។

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៨៧ សម្ដេចព្រះ នរោត្ដម សីហនុ បានប្រកាសថា ព្រះអង្គបញ្ឈប់រាល់សកម្មភាពផ្នែកការទូត និងនយោបាយទាំងអស់ក្នុងនាមរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ សម្រាប់រយៈពេល១២ខែ គឺចាប់ពីថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៨៧ ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៨៨។២៤

ព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្ដម សីហនុ អតីតព្រះមហាក្សត្រ ព្រះអង្គមានព្រះបន្ទូលថា សេចក្ដីសម្រេចព្រះទ័យរបស់ព្រះអង្គ គឺដោយសារមានការរំលោភសិទ្ធិមនុស្សផតស្រាកស្រាន្ត មិនមែនទៅលើកងកម្លាំងសីហនុនិយមតែប៉ុណ្ណោះទេ ប៉ុន្តែទៅលើជនស៊ីវិល ដែលកំពុងរស់នៅតាមជំរំជនភៀសខ្លួនក្នុងតំបន់គ្រប់គ្រងដោយភាគីកម្ពុជាប្រជាធិបតេយ្យ នៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ។

សេចក្ដីសម្រេចព្រះទ័យរបស់ ព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្ដម សីហនុ អតីតព្រះមហាក្សត្រ បានធ្វើឱ្យម្ចាស់ជំនួយឧបត្ថម្ភគាំទ្រសំខាន់ៗរបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ កិច្ចប្រជុំជាច្រើនបានរៀបចំធ្វើឡើងនៅតាមរដ្ឋធានីនៃប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន នាពេលនោះ ហើយសេចក្ដីសម្រេចចិត្តមួយបានធ្វើឡើងដោយការបញ្ជូនគណៈប្រតិភូឥណ្ឌូនេស៊ី និងថៃ ទៅកាន់ទីក្រុងព្យុងយ៉ាងនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ ដើម្បីធ្វើការពិគ្រោះយោបល់ជាមួយ សម្ដេចព្រះ នរោត្ដម សីហនុ និងស្វែងរក ដំណោះស្រាយថាតើមានអ្វីខ្លះដែលអាចធ្វើបាន ដើម្បីដោះស្រាយក្ដីកង្វល់របស់ព្រះអង្គ។

គឺនៅពេលនោះហើយដែលព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្ដម សីហនុ អតីតព្រះមហាក្សត្រ បានសម្រេចព្រះទ័យបញ្ជូនព្រះមហេសីរបស់ព្រះអង្គក្នុងនាមជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ក្នុងបេសកកម្មមួយទៅកាន់ប្រទេសថៃ ដើម្បីធ្វើការពន្យល់ដល់អ្នកគាំទ្ររបស់ជំរំហ្វ៊ុនស៊ិនប៉ិច ថាហេតុអ្វីបានជាព្រះអង្គសម្រេចព្រះទ័យប្រកាន់យកជំហរដ៏តឹងរ៉ឹងបែបនេះ។ ក្នុងខណៈនោះ សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គទទួលព្រះរាជកិច្ចពន្យល់អំពីការសម្រេចព្រះទ័យរបស់សម្ដេចព្រះ នរោត្ដម សីហនុ ទៅកាន់អាជ្ញាធរថៃដែលពាក់ព័ន្ធនឹងបញ្ហានេះ។

ក្នុងអំឡុងកិច្ចប្រជុំនៅក្នុងទីក្រុងបាងកកជាមួយរដ្ឋមន្ត្រីការបរទេសថៃ លោក ស៊ិទ្ធិ សាវិតសិលា អ្នកតំណាងសហរដ្ឋអាមេរិក មន្ត្រីការទូតជាន់ខ្ពស់បារាំង និងរដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី លោកបណ្ឌិត ម៉ុកតារ គូស៊ូម៉ាតម៉ាដជា ដែលបានធ្វើដំណើរពិសេសមួយដើម្បីទៅជួបសវនាការជាមួយសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ បានរៀបរាប់ក្បោះក្បាយអំពីព្រះហឫទ័យកង្វល់ទាំងឡាយដែលនាំឱ្យសម្តេចព្រះ នរោត្តម សីហនុ ត្រូវតែប្រកាន់យកជំហរការពារសិទ្ធិមនុស្សនៃជនភៀសខ្លួនកម្ពុជា ដែលកំពុងរស់នៅតាមជំរំក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។

សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គទទួលបានការអញ្ជើញយាងបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសម៉ាឡេស៊ី ដើម្បីជួបធ្វើសវនាការជាមួយ ដាតូ ស៊េរី បណ្ឌិត ម៉ាហាធៀរ មហាម៉ាត់ ដែលជានាយរដ្ឋមន្ត្រីនាពេលនោះ។ ដាតូ ស៊េរី បណ្ឌិត ម៉ាហាធៀរ មហាម៉ាត់ បានបញ្ជូនយន្តហោះពិសេសមួយគ្រឿងមកទីក្រុងបាងកក ដើម្បីនាំយកសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និងមន្ត្រីហែហមរបស់ព្រះអង្គយាងទៅកាន់ទីក្រុងកូឡាឡាំពួរ។

កិច្ចពិភាក្សារបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៅទីក្រុងបាងកក និងទីក្រុងកូឡាឡាំពួរសម្រេចបានជោគជ័យល្អណាស់ ដោយមានការគាំទ្រពីសំណាក់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន ជាមួយនឹងជំហរម៉ឺងម៉ាត់ចំពោះការរំលោភសិទ្ធិមនុស្សពីសំណាក់ភាគីកម្ពុជាប្រជាធិបតេយ្យ ទៅលើជំរំជនភៀសខ្លួនក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ក៏ដូចជាការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដែលកំពុងស្ថិតក្រោមការកាន់កាប់របស់បរទេស។

កិច្ចពិភាក្សាក្រោយមកទៀតរវាងព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ និងរដ្ឋមន្ត្រីឥណ្ឌូណេស៊ី និងថៃ នៅទីក្រុងព្យុងយ៉ាង បានបង្កើតឡើងនូវផែនទីបង្ហាញផ្លូវមួយ ដែលនាំឱ្យមានជុំទីមួយនៃកិច្ចពិភាក្សាគ្នាក្នុងចំណោមភាគីកម្ពុជាទាំងអស់ក្រោមព្រះរាជធិបតីភាពរបស់ព្រះអង្គ នៅទីក្រុងហ្វែរអង់តាដេន៍ស៍ ប្រទេសបារាំង នៅខែធ្នូ ឆ្នាំ១៩៨៧ និងកិច្ចប្រជុំច្រើនលើកក្រោយមកទៀតរហូតដល់ សម្រេចបាននូវកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ឆ្នាំ១៩៩១។

មិនថាក្នុងព្រះរាជតួនាទីជាព្រះមហាក្សត្រី ជាព្រះមាតា ជាឯកអគ្គរាជទូត ឬជាសម្តេចម៉ែ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គតែងតែគោរពតាមគោលការណ៍គ្រឹះជាសារវន្តមួយជាត្រីវិស័យនាំផ្លូវព្រះអង្គ នោះគឺ បំពេញករណីយកិច្ចជូនប្រទេសជាតិ និងប្រជាជនកម្ពុជា និងជូនស្ថាប័នព្រះមហាក្សត្រ ដែលបានឆ្លងកាត់ទុក្ខលំបាកគ្រប់បែបយ៉ាង រួមមាន ការទម្លាក់គ្រាប់បែករបស់បរទេស សង្គ្រាម អំពើប្រល័យពូជសាសន៍ និងការឈ្លានពានគ្រប់គ្រងទឹកដីដោយជនបរទេស។ ទាំងអស់នេះគឺជាព្រះរាជសមិទ្ធផល ដែលពិតជាទីមោទនភាពសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។



*សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គមានព្រះវត្តមានជាមួយសម្ដេចព្រះមហាក្សត្រ សម្ដេចឪ ក្នុងកិច្ចប្រជុំជាលើកដំបូងរវាងភាគីកម្ពុជាទាំងអស់ រួមមាន នាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណៈប្រតិភូរបស់លោក នៅហ្វ៊ែរអង់តាដេន័ស៍ នៅខែធ្នូ ឆ្នាំ១៩៨៧។*





*(រូបរាប់ពីឆ្វេង ទំព័រ៦២) សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គយាងអមដំណើរសម្ដេចព្រះមហាក្សត្រ សម្ដេចឪ និងព្រះអង្គម្ចាស់ក្សត្រីយ៍ ម៉ាហ្គារេត ចក្រភពអង់គ្លេស ក្នុងអំឡុងពេលដែលព្រះអង្គម្ចាស់ក្សត្រីយ៍ យាងព្រះរាជទស្សនកិច្ចនៅប្រាសាទអង្គរនៅឆ្នាំ១៩៦៨។ (រូបរាប់ពីស្ដាំ) សម្ដេចព្រះមហាក្សត្រ សម្ដេចម៉ែ និងព្រះអង្គម្ចាស់ក្សត្រីយ៍ អាន ចក្រភពអង់គ្លេស ក្នុងអំឡុងពេលព្រះរាជទស្សនកិច្ចរបស់ព្រះអង្គមកកាន់ប្រទេសកម្ពុជា។ (រូបខាងក្រោម) សម្ដេចព្រះមហាក្សត្រី សម្ដេចម៉ែ ព្រះអង្គយាងទទួលស្វាគមន៍ព្រះអង្គម្ចាស់ក្សត្រីយ៍ អាស្ទ្រីដ នៃប្រទេសប៊ែលហ្ស៊ិក នៅព្រះរាជដំណាក់របស់ព្រះអង្គ នៅខែមេសា ឆ្នាំ២០១៣។*






(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គទទួលបានការធ្វើបដិសណ្ឋារកិច្ចនៅពេលព្រះអង្គយាងទៅដល់ទីក្រុងកូឡាឡាំពួរ នៅឆ្នាំ១៩៨៤។ (រូបខាងក្រោម) ក្នុងសវនាការជាមួយ ទុនគុ អាប់ឌុល រ៉ាម៉ាន់ បិតាស្ថាបនិកប្រទេសម៉ាឡេស៊ី នៅទីក្រុងប៉េណាំង ឆ្នាំ១៩៨៤។



**AMBASSADOR**

**EMBASSY OF MALAYSIA**
**BANGKOK**

1 July, 1987.

Your Royal Highness,

I have the honour to convey to you the following telegram which I have received from the Honourable Prime Minister of Malaysia.

<u>Quote</u>:

Your Royal Highness Princess Monique,

Your Royal Highness, I have great honour and pleasure to extend to your Royal Highness an invitation to visit Malaysia on July 3, 1987 as guest of the Government of Malaysia.

The visit by Your Royal Highness will provide a valuable opportunity for us to renew our friendship as well as to exchange views on the latest development on Kampuchea.

I look forward to meeting Your Royal Highness in Kuala Lumpur.

Please accept Your Royal Highness, the assurances of my highest consideration and respect.

Sgd.
Dato' Seri Dr. Mahathir Mohamad

<u>Unquote</u>

Please accept Your Royal Highness, the assurances of my highest consideration.

(Bakri Aiyub Ghazali)
Ambassador

HRH Princess Monique
<u>BANGKOK</u>.

No. 0305/๕๔๕๘๓

Ministry of Foreign Affairs
Saranrom Palace, Bangkok.

๒๓ July B.E. 2530 (1987)

Your Royal Highness,

I have the honour to acknowledge with sincere thanks the message from Your Royal Highness dated 4 July 1987. The Thai Government and people were very pleased to have the opportunity of welcoming Her Royal Highness Princess Monique to Thailand, where she represented Your Royal Highness with distinction during this visit. The presence of Her Royal Highness at the Thai-Kampuchean border helped to boost the morale of the Kampuchean people, who have always looked to Your Royal Highness as the source of their hope for the rebirth of an independent and peaceful Kampuchea.

I look forward to the honour and pleasure of having an audience with Your Royal Highness in Pyongyang in August.

Please accept, Your Royal Highness, the renewed assurances of my highest consideration.

Air Chief Marshal

(Siddhi Savetsila)
Minister of Foreign Affairs of Thailand

H.R.H. Prince Norodom Sihanouk,
President of Democratic Kampuchea,
DEMOCRATIC KAMPUCHEA.



(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងព្រះរាជទស្សនកិច្ចនៅរោងចក្រមួយ នៅប្រទេសសូម៉ាលី ក្នុងទសវត្សរ៍ឆ្នាំ១៩៧០។ (រូបខាងក្រោម) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងអមព្រះរាជដំណើរសម្តេចព្រះមហាក្សត្រ សម្តេចឪ ក្នុងការធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវអង្គការសហប្រជាជាតិក្នុងពិធីជប់លៀង នៅខែតុលា ឆ្នាំ១៩៧៥។





*រូបខាងលើ៖ ក្នុងអំឡុងពេលព្រះរាជទស្សនកិច្ចទៅកាន់អតីតយូហ្គោស្លាវី ក្នុងឆ្នាំ១៩៧៣ សម្តេចព្រះមហាក្សត្រ សម្តេចឪ និង សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ត្រូវបានទទួលស្វាគមន៍ជាភ្ញៀវកិត្តិយស របស់លោកប្រធានាធិបតី  ចូស៊ីប ប្រូស ទីតូ និង  ជំទាវ។ (រូបខាងក្រោម) ព្រះរាជដំណាក់គន្ធបុប្ផានៅក្នុងបរិវេណព្រះបរមរាជវាំង ក្នុងរាជធានីភ្នំពេញ។ សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គបានគង់នៅក្នុងព្រះរាជដំណាក់នេះតាំងពីឆ្នាំ២០០៤មក បន្ទាប់ពីសម្តេចព្រះមហាក្សត្រ សម្តេចឪ ព្រះអង្គបានដាក់រាជ្យសម្បត្តិ។*





*សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងទទួលស្វាគមន៍ប្រជាជន ក្នុងបរិវេណព្រះបរមរាជវាំង នៅឆ្នាំ២០០០។*





*(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងទទួលស្វាគមន៍ព្រះអង្គម្ចាស់ក្សត្រិយ៍ មហាចក្រី សិរិនថន នៃព្រះរាជាណាចក្រថៃឡង់ដ៍ នៅខែកុម្ភៈ ឆ្នាំ២០១៦។ (រូបខាងក្រោម) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងចូលរួមក្នុងព្រះរាជពិធីសូត្រមន្តនៅក្រៅបរិវេណព្រះបរមរាជវាំង បន្ទាប់ពីការសោយព្រះទិវង្គតរបស់ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ នៅខែតុលា ឆ្នាំ២០១២។*





សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១។ (រូបថតដោយ ម៉ក់ រ៉េមីសា)



(រូបខាងលើ) សម្តេចព្រះមហាក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៅឆ្នាំ២០០៤។

(រូបខាងក្រោម) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ព្រះអង្គយាងធ្វើជាព្រះអធិបតីក្នុងពិធីផ្លូវការនៅឆ្នាំ២០០១។





ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី
និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ អមដោយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក
ប្រចាំនៅកម្ពុជា ក្នុងការទទួលស្វាគមន៍សមាជិកកងកម្លាំងទ័ពអាកាសអាមេរិក
ឈ្មោះថា Air Force String Quartet នាទិវាប្រគុំតន្ត្រីមួយនៅទីក្រុងភ្នំពេញ
នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៦។ (រូបថតផ្តល់ដោយស្ថានទូតសហរដ្ឋអាមេរិក
ប្រចាំនៅកម្ពុជា)





*(រូបខាងលើ) ព្រះករុណាព្រះមហាក្សត្រ នរោត្តម សីហមុនី និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ អមដោយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ក្នុងការទទួលស្វាគមន៍សមាជិកកងកម្លាំងទ័ពអាកាសអាមេរិកឈ្មោះថា* Air Force String Quartet *នាទិវាប្រគុំតន្ត្រីមួយនៅភ្នំពេញ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៦ (រូបថតផ្តល់ដោយស្ថានទូតសហរដ្ឋអាមេរិក)។ (រូបខាងក្រោម) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ យាងទទួលស្វាគមន៍ប្រជាពលរដ្ឋនៅក្នុងព្រះបរមរាជវាំង នៅឆ្នាំ២០០០។*





*(រូបខាងលើ) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ទទួលស្វាគមន៍សមាជិកក្រុមបាល់បោះនារីលើរទេះកង់មកពីខេត្តបាត់ដំបង នៅខែមេសា ឆ្នាំ២០១៦។ (រូបខាងក្រោម) សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ និងព្រះអង្គម្ចាស់ អាគីហ្សីណូ ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះចៅអធិរាជនៃប្រទេសជប៉ុន នៅក្នុងព្រះរាជពិធីបុណ្យសពព្រះបាទសម្តេចព្រះ នរោត្តម សីហនុ សម្តេចឪ។*






ព្រះឆាយាលក្ខណ៍របស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ នៅរាជធានីភ្នំពេញ។

# ពង្សាវតាររបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ

# ពង្សាវតាររបស់សម្តេចព្រះមហាក្សត្រី សម្តេចម៉ែ

**ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម**

ព្រះអង្គម្ចាស់ នរោត្តម ដួងចក្រ និងកញ្ញា អ៊ួក *(អាពាហ៍ពិពាហ៍លើកទី១)*

ព្រះអង្គម្ចាស់ នរោត្តម រង្សាវ៉ាស៊ី *(សុគតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤០)*

ព្រះនាងម្ចាស់ ផៃភ័ក្រ *(សុគតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០)*

លោក ពាង និងលោកស្រី អ៊ួក *(អាពាហ៍ពិពាហ៍លើកទី២)*

កញ្ញា ប៉ុម ពាង (១៩០៤-១៩៩១) និងលោក អោម ផាន់កែវ *(អាពាហ៍ពិពាហ៍លើកទី១)*

លោក ហេល ពាង *(កើតនៅឆ្នាំ១៩០៦ និងទទួលមរណភាពក្នុងទសវត្សរ៍ឆ្នាំ៦០)*

លោក អោម ម៉ាន្ទីន *(កើតនៅឆ្នាំ១៩២៤)*

លោក អោម វិណ្ណារិុធ *(កើតនៅឆ្នាំ១៩២៥ ហើយត្រូវបានវៀតមិញសម្លាប់នៅ ខេត្តកំពត ឆ្នាំ១៩៤៨)*

កញ្ញា អោម នារីវ៉ាន់ *(១៩២៦-១៩៤៥)*

លោក អោម សួរក្ស សានថាន់ *(កើតនៅឆ្នាំ១៩២៧ ហើយត្រូវបានខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៨)*

កញ្ញា អោម សុផានិត *(១៩២៨-២០១៣)*

លោក ហ្សង់-ហ្វ្រង់ស្វ័រ អ៊ីហ្ស៊ី និងអ្នកស្រី ប៉ុម ពាង *(អាពាហ៍ពិពាហ៍លើកទី២)*

កញ្ញា អាន់-ម៉ារី អ៊ីហ្ស៊ី និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មេង្គរី *(ទាំងពីរព្រះអង្គត្រូវបានខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៨)*

កញ្ញា ប៉ូល ម៉ូនិក អ៊ីហ្ស៊ី និង**ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** *(ប្រសូតនៅឆ្នាំ១៩៥៣)*

ព្រះអង្គម្ចាស់ សម្តេចព្រះ នរោត្តម នរិន្ទ្រពង្ស *(១៩៥៤-២០០៣)*

# អវសានកថា

១. កាសែត ភ្នំពេញប៉ុស្តិ៍ លេខ៤/៨ ចុះផ្សាយនៅថ្ងៃទី២១ ខែមេសា និងនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩៥

២. ទីភ្នាក់ងារសារព័ត៌មាន អាសូស៊ីអេតប្រេស ឬ Associated Press ចុះផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩

៣. កាសែត ខេមបូឌាដេលី ឬ The Cambodia Daily ចុះផ្សាយនៅថ្ងៃទី៨ កញ្ញា ឆ្នាំ១៩៩៩

៤. ទស្សនាវដ្តីថាម៍ បំណងជើងថា "ម៉ូនិក ជួបជាមួយព្រះមហាក្សត្រ" ចុះផ្សាយនៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៥៦ ទំព័រលេខ៨

៥. ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ «ការស្រាយបំភ្លឺអំពីព្រះអគ្គមហេសីរបស់ខ្ញុំ» ព្រឹត្តិបត្រប្រចាំខែ ក្រុងប៉េកាំង ចុះនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៣

៦. ស្ទួន អាយប៊ីអាយឌី., ទំព័រលេខ១១

៧. ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ, អូភី. ស៊ីអាយធី., ទំព័រលេខ១២

៨. ស្ទួន អាយប៊ីអាយឌី.,

៩. ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ «តន្ត្រី និងចម្រៀង» នៅភ្នំពេញ នៅឆ្នាំ១៩៦៩ ចុះផ្សាយជាលក្ខណៈឯកជន ទំព័រលេខ១១២

១០. ស្ទួន អាយប៊ីអាយឌី., ទំព័រលេខ១៧

១១. កាសែត ហ្សេរុយសាឡិមប៉ុស្តិ៍ ឬ The Jerusalem Post ចុះផ្សាយនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧២ ទំព័រលេខ១៧ និងកាសែតញូវយ៉កថាម៍ ឬ The New York Times ចុះផ្សាយនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៧២ ទំព័រលេខ១៥២

១២. កាសែតញូវយ៉កថាម៍ ឬ The New York Times ស្ទួន

១៣. កាសែតញូវយ៉កថាម៍ ឬ The New York Times ស្ទួន

១៤. កាសែតញូវយ៉កថាម៍ ឬ The New York Times អូភី. ស៊ីអាយធី.,

១៥. ទស្សនាវដ្តី The New Leader ចុះផ្សាយនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧០ ទំព័រ៦-៧

១៦. អត្ថបទរបស់លោក អេហែន ថូម៉ាស់ អិល. បំណងជើងថា "សំណួរល្អ និងចម្លើយខុស" ឯកសារស្រាវជ្រាវស្តីពីព័ត៌មានសម្ងាត់ របស់មជ្ឈមណ្ឌលស្រាវជ្រាវ និងសិក្សាអំពីការស៊ើបការសម្ងាត់ នៃភ្នាក់ងារស៊ើបការសម្ងាត់អាមេរិក ឬ ស៊ីអាយអេ ចុះផ្សាយ នៅខែកុម្ភៈ ឆ្នាំ២០០៤ ទំព័រលេខ១៧-១៨

១៧. ស្ទួន

១៨. ស្ទួន អូភី. ស៊ីអាយធី., ទំព័រលេខ១១៨។

១៩. កាសែតញូវយ៉កថាម៍ ឬ The New York Times ចុះផ្សាយនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧០ ទំព័រលេខ១៩

២០. ស្ទួន

២១. ទស្សនាវដ្តី Far Eastern Economic Review ហុងកុង ចុះផ្សាយនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦

២២. កាសែត ភ្នំពេញប៉ុស្តិ៍ អូភី. ស៊ីអាយធី.,

២៣. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រាទី១៥

២៤. សេចក្តីថ្លែងការណ៍របស់សម្តេចព្រះបាទ នរោត្តម សីហនុ នៃព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងប៉េកាំង ចុះផ្សាយនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៨៧។

9 789924 907800 >